**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ (ចាប់ពីឆ្នាំ២០១៥-២០២០)

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងដោយទឡើងដោយ

និស្សិតឈ្មោះ **ក. ឡេង លក្ខ**

**ក. ហ៊ុល រស្មី**

សាស្ត្រាចារ្យណែនាំ

**លោក យ៉ុង និល**


ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ

ជំនាន់ទី១៣

ឆ្នាំចូលរៀន ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីអំណរអំណាច

នាងខ្ញុំទាំងពីរឈ្មោះ **ឡេង ល័ក្ខ** និង **ហ៊ុល រស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៣ (២០១៦-២០២០) នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានសម្រេចនូវការស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សាមួយ ស្តីអំពី "**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ** (**ចាប់ពីឆ្នាំ២០១៥-២០២០**)" សម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ។ សារណាបញ្ចប់ការសិក្សានេះ នាងខ្ញុំទាំងពីរបានស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដែលមានទីតាំងនៅឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានសាស្រ្តាចារ្យដឹកនាំដោយ សាស្រ្តាចារ្យ **លោក យ៉ុង និល**។ យើងទាំងពីរសូមទទួលខុសត្រូវទាំងស្រុងចំពោះស្នាដៃសារណាបញ្ចប់ការសិក្សាមួយនេះដោយក្តីរីករាយ និងសូមអះអាងថាសារណានេះវាពិតជាសមិទ្ធផលផ្ទាល់របស់យើងទាំងពីរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៣ (២០១៦-២០២០) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការគោរពប្រណិប័តន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- ❖ លោកឪពុក និងអ្នកម្តាយ ដែលលោកទាំងពីរមានគុណសែនធ្ងន់ ចំពោះកូនបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថ្នាក់ថ្នមថែរក្សា អប់រំទូន្មានប្រៀនប្រដៅ លះបង់កម្លាំងកាយ ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃរបស់លោកទាំងពីរ ពិសេសលើសនេះទៅទៀត លោកទាំងពីរបានផ្តល់នូវលទ្ធភាពគ្រប់បែបយ៉ាងដើម្បីឱ្យកូនបានបន្តការសិក្សាតាំងពីមត្តេយ្យសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា។
- ❖ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង បុគ្គលិកបម្រើការ និងលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ❖ លោកគ្រូ អ្នកគ្រូគ្រប់រូប ដែលបានបង្រៀន តាំងពីមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ។
- ❖ លោកសាស្ត្រាចារ្យ **យ៉ុង និល** ដែលបានបង្រៀន និងបានពន្យល់ណែនាំយ៉ាងលម្អិតលើការស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សា ស្តីពី "**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ (ចាប់ពីឆ្នាំ២០១៥-២០២០)**" នេះឡើង។

ជាចុងក្រោយនាងខ្ញុំទាំងពីរ សូមលើកម្រាមដៃដប់ប្រណម្យជូនពរចំពោះ លោកឪពុក ព្រមទាំងអ្នកម្តាយ គណៈគ្រប់គ្រងនៃសកលវិទ្យាល័យ លោកសាស្ត្រាចារ្យ **យ៉ុង និល** និងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យបានទទួលនូវពុទ្ធពរជ័យគ្រប់ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**

# អារម្ភកថា

នាងខ្ញុំទាំងពីរ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៣ (២០១៦-២០២០) នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** បានសម្រេចនូវការស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ឆ្នាំសិក្សាមួយ ស្ដីអំពី "**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ (ចាប់ពីឆ្នាំ២០១៥-២០២០)**" សម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។

នាងខ្ញុំទាំងពីរមានសេចក្តីសោមនស្សរីករាយជាអនេក ដែលគណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់នូវឱកាសដ៏មានតម្លៃដល់យើងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ មួយវិញទៀត យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សមទ្ធិផលសារណាបញ្ចប់ឆ្នាំសិក្សាស្តីពី "**ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ (ចាប់ពីឆ្នាំ២០១៥-២០២០)**" នេះនឹងផ្តល់នូវផលប្រយោជន៍ដល់ការធ្វើឱ្យមានភាពប្រសើរឡើង នៃស្ថានភាពការគ្រប់គ្រងរដ្ឋបាលឃុំនាពេលបច្ចុប្បន្ន និងពេលអនាគត។ លើសពីនេះ ការចងក្រងនេះនឹងក្លាយជាឯកសារសម្រាប់ការសិក្សា និងស្រាវជ្រាវបន្តដល់សិស្សនិស្សិតជំនាន់ក្រោយ និងមជ្ឈដ្ឋានអ្នកសិក្សានានាជាក់ពុំខានឡើយ។

បើទោះបីជាមានការផ្ចិតផ្ចង់យ៉ាងណាក៏ដោយ នាងខ្ញុំទាំងពីរជឿជាក់ថាកិច្ចការមួយនេះនឹងនៅតែមានចំណុចខ្វះខាត ឬមានចំណុចខុសឆ្គងមួយចំនួនសម្រាប់អ្នកសិក្សាស្រាវជ្រាវ និងគ្រប់មជ្ឈដ្ឋានអ្នកអានជាក់ជាមិនខានឡើយ។ ដើម្បីជាការឆ្លើយតបទៅនឹងកំហុសអចេតនាទាំងនេះ នាងខ្ញុំទាំងពីរសូមអភ័យទោស និងសូមស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យកែលម្អគ្រប់បែបយ៉ាងទាំងអស់។

រាជធានីភ្នំពេញ, ឆ្នាំ២០២០

និស្សិត ឡេង ល័ក្ខ និង ហ៊ុល រស្មី

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................................១

**ជំពូកទី ១**

**ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំអូរឧកញ៉ាហេង**

១.១ ក្រុមប្រឹក្សាឃុំ.........................................................................................................៤

១.២ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា.....................................................................៨

១.២.១ គណៈកម្មាធិការលទ្ធកម្ម.................................................................................៨

១.២.២ គណៈកម្មាធិការគម្រោងមូលនិធិ........................................................................៩

១.២.៣ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ.......................................................៩

១.២.៤ គណៈកម្មាធិការផែនការថវិកា........................................................................១០

១.២.៥ គណៈកម្មាធិការមណ្ឌលសុខភាព......................................................................១១

១.៣ មេឃុំ.....................................................................................................................១១

១.៣.១ ជំទប់ទី១..........................................................................................................១២

១.៣.២ ជំទប់ទី២..........................................................................................................១២

១.៣.៣ ស្មៀន.............................................................................................................១២

១.៣.៤ មេភូមិ.............................................................................................................១៣

១.៤ កិច្ចការរដ្ឋបាលឃុំ.....................................................................................................១៤

**ជំពូកទី ២**

**ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ឃុំអូរឧកញ៉ាហេង**

២.១ ស្ថានភាពទូទៅនៃឃុំអូរឧកញ៉ាហេង..........................................................................១៦

២.១.១ ស្ថានភាពភូមិសាស្ត្រ.......................................................................................១៦

២.១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម....................................................................១៩

២.១.២.១ ស្ថានភាពសេដ្ឋកិច្ច.....................................................................................១៩

២.១.២.២ ស្ថានភាពសង្គមកិច្ច....................................................................................២២

២.២ ការរៀបចំផែនការអភិវឌ្ឍរបស់ឃុំអូរឧកញ៉ាហេង........................................................២៥

២.២.១ ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍ...........................................................................២៥

២.២.២ គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច........................................................................២៦

២.២.៣ គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច........................................................................២៦

២.២.៤ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ........................................................................................................២៦

២.២.៥ គោលដៅអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ........................២៧

២.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍......................................................................................................២៧
២.៣.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច.......................................................................................២៧
២.៣.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច.......................................................................................២៨
២.៣.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការបន្សាំ និងអាកាសធាតុ...២៩
២.៣.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ..............៣០
២.៤ ការគ្រប់គ្រងដីធ្លី បរិស្ថានសាធារណៈការ និងសោភ័ណភាព.....................................................៣១
២.៤.១ ការកាន់កាប់ និងគ្រប់គ្រងដី.............................................................................................៣១
២.៤.២ បរិស្ថាន និងធនធានធម្មជាតិ.............................................................................................៣៣
២.៤.៣ សាធារណៈការ និងសោភណ៍ភាពសង្គម...............................................................................៣៤
២.៥ រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ..........................................................................៣៦
២.៥.១ អភិបាលកិច្ច.......................................................................................................................៣៦
២.៥.២ គ្រប់គ្រងដែនដី....................................................................................................................៣៦
២.៥.៣ ការគ្រប់គ្រងស្ថិតិ..................................................................................................................៣៦
២.៥.៤ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ.......................................................................៣៦

**ជំពូកទី ៣**

**គោលនយោបាយ និងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១៥-២០២០**

៣.១ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ..................................................................................................៣៨
៣.២ កម្មវិធីវិនិយោគបីឆ្នាំរំកិល..........................................................................................................៤០
៣.២.១ យន្តការតាមដាន និងវាយតម្លៃ.............................................................................................៤១
៣.២.២ វិធីសាស្ត្រតាមដាន និងវាយតម្លៃ..........................................................................................៤១
៣.២.៣ សូចនាករតាមដាន និងវាយតម្លៃ..........................................................................................៤១
៣.៣ កម្មវិធីវិនិយោគរបស់ឃុំ...............................................................................................................៤២
៣.៣.១ ការតាមដានពិនិត្យ និងវាយតម្លៃ ..........................................................................................៤៨
៣.៤ របាយការណ៍ប្រចាំខែស្តីពី ការអនុវត្តការងារសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាលសន្តិសុខ ឃុំអូរឧកញ៉ាហេង ឆ្នាំ២០១៩...............................................................................................................................៤៩
៣.៥ ការរៀបចំគម្រោងថវិកា...............................................................................................................៥៧
**សេចក្តីសន្និដ្ឋាននិងអនុសាសន៍** ......................................................................................៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ខេត្តព្រះសីហនុគឺជាស្នាព្រះហស្តរបស់ព្រះបាទនរោត្តម សីហនុ ដែលជាខេត្តស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពត ខាងជើងជាប់នឹងខេត្តកោះកុង ខាងលិច និងខាងត្បូងជាប់នឹងសមុទ្រ។ ផ្ទៃក្រឡាក្រុងកំពង់សោមនៅឆ្នាំ១៩៦២ គឺគេកំណត់យក៦៨,២គីឡូម៉ែត្រការ៉េ តែមកដល់បច្ចុប្បន្ននេះ(អំឡុងឆ្នាំ១៩៨៦) ដោយការបញ្ចូលស្រុកព្រៃនប់នៅក្នុងការគ្រប់គ្រងរបស់ក្រុងទៀតនោះ ផ្ទៃក្រឡារបស់ក្រុងបានពង្រីករហូតដល់ ១.៣០៣ គីឡូម៉ែត្រការ៉េ នាឆ្នាំ១៩៨៦នេះ ។ នៅឆ្នាំ១៩៨២ ការបែងចែករដ្ឋបាលរបស់ក្រុងគឺមានសង្កាត់៧ និងស្រុកព្រៃនប់ តែមកដល់ឆ្នាំ១៩៨៦នេះ យើងឃើញមានស្រុកព្រៃនប់ដែលមាន១៤ឃុំ និងខណ្ឌស្ទឹងហាវ ដែលមាន៣សង្កាត់ និង៤សង្កាត់ទៀតជុំវិញក្រុង ។ដោយស្រុកព្រៃនប់មានឃុំចំនួន០៧ គឺ ឃុំព្រៃនប់ ឃុំអូរឧកញ៉ាហេង ឃុំអូរជ្រៅ ឃុំបឹងតាព្រហ្ម ឃុំបិតត្រាង ឃុំស្មាច់ដែង និងឃុំរាម។ ដោយឡែកឃុំអូរឧកញ៉ាហេងមាន ភូមិចំនួន០៥ គឺ ភូមិអូរឧកញ៉ាហេង ភូមិអូរតាសេក ភូមិអូរតាប៉ាង អូរចំណារ និងភូមិបត់គគីរ។ ចាប់ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ ២០១៥ ឃុំអូរឧកញ៉ាហេងទទួលបានការអភិវឌ្ឍតិចតួចខ្លាំង ដោយសារខ្វះប្រជាពលរដ្ឋយល់ដឹង និងគ្មានអ្នកដែលមានសមត្ថភាពក្នុការដឹកនាំឃុំ និងឈរឈ្មោះតំណាងដើម្បីការបោះឆ្នោតជ្រើសរើស។ នៅចុងអាណត្តិទី ៤ ក្នុងឃុំអូរឧកញ៉ាហេង ក៏ទទួលបានភាពរីកចម្រើនបន្តិចម្តងៗនោះដោយសារភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺការអភិវឌ្ឍន៍ឃុំ សង្កាត់ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ដោយមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ដោយសារតែមានការកែប្រែនូវដែនរដ្ឋបាលគ្រប់គ្រង និងគ្រប់គ្រងក្នុងដែនរដ្ឋបាលថ្មី ដែលសិទ្ធិអំណាច និងការទទួលខុសត្រូវ ក៏ត្រូវបានផ្ទេរ និងត្រូវបានផ្លាស់ប្តូរ ជាពិសេសការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងសេវាសាធារណៈដែលឃុំ សង្កាត់ បានផ្តល់ទៅឱ្យថ្នាក់មូលដ្ឋានដែនដីរបស់ខ្លួនមានការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់ នូវកម្រិតជីវភាពអនាគតភាព និងអន្តរទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធថែមទៀតក្នុងបរិបទវិមជ្ឍការ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការសិក្សាស្រាវជ្រាវលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ (ចាប់ពីឆ្នាំ២០១៥-២០២០)" ឱ្យកាន់តែស៊ីជម្រៅ និងមានភាពច្បាស់លាស់ ចំណោទបញ្ហាត្រូវបានលើកឡើងថា តើការគ្រប់គ្រងរដ្ឋបាលឃុំអូរឧកញ៉ាហេងមានលក្ខណៈយ៉ាងណាខ្លះ បើតាមអត្ថបទគតិយុត្ត ឬទ្រឹស្តី? ហើយតើការរៀបចំរដ្ឋបាលឃុំសង្កាត់មានដំណើរការយ៉ាងដូចម្តេចដែរ ក្នុងការអនុវត្តសម្រាប់ការអភិវឌ្ឍន៍ដើម្បីឆ្លើយតបទៅនឹងសេចក្តីតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង តាមរយៈផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែករដ្ឋបាល និងសន្តិសុខ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន និងផ្នែកយេនឌ័រ? តើឃុំទទួលបានការអភិវឌ្ឍអ្វីខ្លះហើយ? តើប្រជាជនដែលរស់នៅទីនោះមានការពេញចិត្តដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះគឺមានគោលបំណងក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត ដើម្បីស្វែងយល់អំពីការគ្រប់គ្រងឃុំមួយដោយផ្ទាល់ និងបញ្ហាផ្សេងៗដែលឃុំបានជួបប្រទះនិងដំណើរការអភិវឌ្ឍឃុំ និងបាន

ស្វែងយល់ពីរបៀបគ្រប់គ្រងឃុំ និងស្វែងរកចំណុចខ្សោយនៃការផ្ទេរមជ្ឈការទៅឲ្យឃុំសង្កាត់។ ការស្រាវជ្រាវនេះផងដែរ គឺធ្វើការវាយតម្លៃទៅលើចំណុចទាំងឡាយ ដើម្បីស្វែងរកចំណុចខ្វះខាតដែលត្រូវកែលម្អ ព្រមទាំងធ្វើសេចក្តីសន្និដ្ឋាននិងផ្តល់ជាអនុសាសន៍ទៅលើចំណុចគួរកែលម្អ។

## ៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើប្រធានបទស្តីពី ការគ្រប់គ្រងឃុំអូរឧកញ៉ាហេង និងការភិវឌ្ឍ ដែលត្រូវបានកំណត់យកចាប់ពីឆ្នាំ២០១៥ ដល់ ២០២០ ដោយធ្វើការវែកញែកឲ្យច្បាស់អំពីដំណើរការក្នុងការគ្រប់គ្រង និងស្វែងរកហានិភ័យនៅក្នុងឃុំ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់សម្រាប់សង្គម បុគ្គល និងជាការដកស្រង់នូវបទពិសោធន៍ពីការយល់ដឹងអំពីការគ្រប់គ្រងឃុំអូរឧកញ៉ាហេង និងការអភិវឌ្ឍ ក្នុងឆ្នាំ២០១៥ ដល់ ២០២០។ ការសិក្សានេះផ្តល់សារៈប្រយោជន៍ចំពោះ៖

អ្នកសិក្សាស្រាវជ្រាវ៖ បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនេះបានធ្វើឲ្យយើងយល់កាន់តែច្បាស់អំពីការគ្រប់គ្រងរដ្ឋបាលឃុំនិងការអភិវឌ្ឍឃុំ។ ផ្តល់នូវបទពិសោធន៍ ចំណេះដឹងជាក់ស្តែង ក្នុងការអភិវឌ្ឍទៅថ្ងៃអនាគត និងចងក្រងទុកជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយ។

សង្គម៖ អាចបង្ហាញទិន្នន័យពិតប្រាកដ និងជាក់ស្តែងដល់បណ្តាពាក់ពន្ធ័ផ្សេងៗ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវគឺស្រាវជ្រាវតាមបែបទិន្នន័យបន្ទាប់បន្សំដោយធ្វើការចុះទៅអង្កេតនិងស្រាវជ្រាវនៅសាលាឃុំដោយផ្ទាល់និងធ្វើការស្នើសុំឯកសារផ្សេងៗពីឃុំ ដោយការពិភាក្សា និងទទួលបានការណែនាំពីសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យនានា និងការស្រាវជ្រាវឯកសារទាក់ទងដែលមាននៅក្នុងបណ្ណាល័យនានា ជាពិសេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមប្រព័ន្ធអេឡិចត្រូនិច ស្វែងរកព័ត៌មាននានាតាមបណ្តាគេហទំព័រ ដែលនិយាយពីបញ្ហាពាក់ព័ន្ធ ដើម្បីធ្វើឲ្យប្រធានបទកាន់តែមានភាពស៊ីជម្រៅ និងផ្តល់ជាសៀវភៅមួយដែលអាចទុកជូនអ្នកស្រាវជ្រាវផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការរៀបចំនៃឯកសារស្រាវជ្រាវនេះគឺ ចែកចេញជា៣ជំពូកដូចខាងក្រោម៖

ជំពូកទី១៖ ដំណើរការគ្រប់គ្រងរដ្ឋនាលឃុំអូរឧកញ៉ាងហេង ដែលពិពណ៌នាពីក្រុមប្រឹក្សា គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា តួនាទី មេឃុំ ស្មៀន និងជំទប់ទី១ ជំទប់ទី២ និងកិច្ចការរដ្ឋបាលឃុំ ។

ជំពូលទី២៖ ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ឃុំអូរឧកញ៉ាហេង ដែលពិពណ៌នាពីស្ថានភាពទូទៅនៃឃុំអូរឧកញ៉ាហេង ការរៀបចំផែនការអភិវឌ្ឍន៍ យុទ្ធសាស្ត្រ និងគោលបំណងរបស់ឃុំអូរឧកញ៉ាហេងក្នុងការអនុវត្តការងារ។

ជំពូកទី៣៖ គោលនយោបាយ និងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១៥-២០២០ ដែលពិពណ៌នាពីផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល កម្មវិធីវិនិយោគឃុំ របាយការណ៍ប្រចាំ

ខែស្ដីពី ការអនុវត្តការងារសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាលសន្តិសុខ ឃុំអូរឧកញ៉ាហេងឆ្នាំ ២០១៩ និងការរៀបចំគម្រោងថវិកា។

# ជំពូកទី ១

# ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំអូរឧកញ៉ាហេង

ឃុំអូរឧកញ៉ាហេង គឺជាឃុំ មួយក្នុងចំណោមឃុំ សរុប១៤ នៃស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានព្រំប្រទល់ខាងកើតទល់នឹងឃុំបឹងតាព្រហ្ម ខាងជើងទល់នឹងឃុំព្រៃនប់ ខាងលិចទល់នឹងឃុំរាម (ព្រែកទឹកសាប) និងខាងត្បូងទល់នឹងឃុំរាម (សមុទ្រ)។

## ១.១ ក្រុមប្រឹក្សាឃុំ

យោងតាមប្រកាសមហាផ្ទៃ[9] បានទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ ជំនប់ និងសមជិកក្រុមប្រឹក្សាឃុំ នៃឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីនុ បានប្រគល់តួនាទី និងភារកិច្ច ជូនសមាសភាព ៧រូប ដូចមានរាយនាមខាងក្រោម៖

១ លោក កៅ ឡេង ប្រធានក្រុមប្រឹក្សា និងជាមេឃុំ ទទួលខុសត្រូវរួមលើការងារទាំងអស់នឹងការងារមួយចំនួនទៀតដូចខាងក្រោម៖

- កៀងគរធនធានសមត្ថភាពពីប្រភពនានាទាំងក្នុងនិងក្រៅឃុំនិងស្វែងរកការចូលរួមភាពជាដៃគូដឹកនាំដើម្បីអភិវឌ្ឍន៍ឃុំ
- ទទួលខុសត្រូវលើការអនុវត្តផែនការនិងគម្រោងអភិវឌ្ឍន៍របស់ឃុំនិងថវិកាឃុំ
- ទទួលខុសត្រូវលើកិច្ចការមួយចំនួនទៀតមានចែងក្នុងមាត្រា ២០ នៃអនុក្រឹត្យលេខ ២២
- ទទួលខុសត្រូវលើកិច្ចការផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន។

២ លោក ហែម សារ៉ាត់ សមាជិកក្រុមប្រឹក្សា និងជាជំទប់ទី ១ មានតួនាទីនឹងភារកិច្ចជំនួយការជូនមេឃុំលើបញ្ហាសេដ្ឋកិច្ចហិរញ្ញវត្ថុ និងកសិកម្មដូចខាងក្រោម៖

- គ្រប់គ្រងស្ថិតិគ្រប់វិស័យ និងស្តាប់សក្តានុពលសេដ្ឋកិច្ចក្នុងឃុំ
- គ្រប់គ្រងរដ្ឋបាលលើសកម្មភាពរបស់អង្គភាពលទ្ធកម្ម សេវាកម្មអាជីវកម្មក្នុងឃុំ
- ពិនិត្យពាក្យសុំកាន់កាប់ដីធ្លីការសាងសង់ការរុះរើការជួសជុល និងការកែលំអសំណង់នានាក្នុងឃុំ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ និងអចលនទ្រព្យរបស់ឃុំ
- រៀបចំ និងចាត់ចែងការប្រមូលទុនចូលរួមរបស់ប្រជាពលរដ្ឋលើតម្លៃគម្រោង
- រៀបចំ និងគ្រប់គ្រងថវិកាចំណូលចំណាយប្រចាំខែប្រចាំឆ្នាំរបស់ឃុំ
- រៀបចំរបាយការណ៍ថវិកាស្តីពីចំណូលចំណាយប្រចាំខែប្រចាំឆ្នាំ និងការបិទបញ្ជីថវិកាឆ្នាំប្រជាជនបង្គោលគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់មេឃុំ។

[9]ប្រការ១ នៃប្រកាសរបស់មហាផ្ទៃ លេខ ៨៧០៦ ប្រក ចុះថ្ងៃទី២០ ខែធ្នូ ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ ជំនប់ និងសមជិកក្រុមប្រឹក្សាឃុំ នៃឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីនុ

៣ លោក ងួន សំអាត សមាជិកក្រុមប្រឹក្សានិងជាជំទប់ទី ២ មានតួនាទីនិងភារកិច្ចជំនួយការជួលមេឃុំលើបញ្ហាដែលពាក់ព័ន្ធការរដ្ឋបាលសេវាសាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈដូចខាងក្រោមៈ

- ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ
- សម្រួលផ្សះផ្សាទំនាស់ផ្សេងៗក្នុងសមត្ថកិច្ចរបស់ឃុំ
- រៀបចំកម្មវិធីការងាររៀបចំប្រជុំចាត់ចែងវេនប្រចាំការក្នុងសាលាឃុំ និងទំនាក់ទំនងសាធារណៈ
- ការពារសន្តិសុខសណ្តាប់ធ្នាប់ និងសោភ័ណភាពអនាម័យសាលាឃុំ
- បូកសរុបរបាយការណ៍សភាពការណ៍ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ
- លិខិតចេញចូលលិខិតរដ្ឋបាលផ្សេងៗ និងទុកដាក់ដំកល់ឯកសារលិខិតស្នាមឲ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ
- ការងារផ្សព្វផ្សាយព័ត៌មាន និងត្រួតពិនិត្យការប្រើប្រាស់ក្តារព័ត៌មានភូមិ
- គ្រប់គ្រងការងារអគ្គិភ័យ និងគ្រោះកូលដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យរបស់មេឃុំ។

៤ លោកឡា សាញ់ សមាជិកក្រុមប្រឹក្សាឃុំ មានតួនាទីភារកិច្ចជំនួយការជូនមេឃុំលើការងារដូចខាងក្រោមៈ

- រៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ
- គ្រប់គ្រងទិន្នន័យភូមិនិងស្ថិតិ
- សម្របសម្រួលសហការជាមួយមន្ទីរ អង្គការសង្គមស៊ីវិលផ្នែកឯកជន និងសម្រង់ជនលើសកម្មភាពអភិវឌ្ឍន៍ឃុំ
- ទទួលបន្ទុកការងារប្រចាំឃុំអូតាសេក
- ជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ឃុំ
- ជាតំណាងម្ចាស់គម្រោងរបស់ឃុំ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យរបស់ឃុំ។

៥ លោកស្រី ទាវ ណៃហ៊ាង សមាជិកក្រុមប្រឹក្សាឃុំ មានតួនាទី និងភារកិច្ចជំនួយការជូនមេឃុំលើការងារដូចខាងក្រោមៈ

- ការងារសុខាភិបាលនិងសុខភាពសាធារណៈ
- ការងារធម្មការ និងវិចិត្រសិល្បៈ
- ចាប់ពីថ្ងៃការជួយសង្គ្រោះប្រជាពលរដ្ឋពេលមានគ្រោះធម្មជាតិឬគ្រោះថ្នាក់ផ្សេងៗ
- ការងារយេនឌ័រ
- ទទួលបន្ទុកការងារប្រចាំភូមិបត់គគីរ
- ទទួលបន្ទុកការងារអប់រំយុវជន និងកីឡានិងអក្ខរកម្ម
- ទេសចរណ៍ និងការងារបេតិកភណ្ឌរមណីយដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រនានា

- បំពេញភារកិច្ចផ្សេងៗទៀតប្រគល់ឲ្យរបស់មេឃុំ ។

ពាក់ព័ន្ធកិច្ចការរដ្ឋបាលសេវាសាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈដូចខាងក្រោម៖

- ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
- សម្របសម្រួលផ្សះផ្សាទំនាស់ផ្សេងៗក្នុងសេដ្ឋកិច្ចរបស់ឃុំ
- រៀបចំកម្មវិធីការងារការប្រជុំចាត់ចែងវេនប្រចាំការក្នុងសាលាឃុំ និងទំនាក់ទំនងសាធារណៈ
- ការពារសន្តិសុខសណ្តាប់ធ្នាប់ និងសោភ័ណភាពអនាម័យសាលាឃុំ
- បូកសរុបរបាយការណ៍សភាពការណ៍ និងរបាយការណ៍ប្រចាំខែប្រចាំឆ្នាំ
- លិខិតចេញចូលនិខិតរដ្ឋបាលផ្សេងៗ និងទុកដាក់ដំកល់ឯកសារលិខិតស្នាមឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ
- គ្រប់គ្រងការងារអត្រានុកូលដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យរបស់មេឃុំ។

៦ លោក គឹម វណ្ណារិទ្ធ សមាជិកក្រុមប្រឹក្សាឃុំ មានតួនាទីភារកិច្ចជំនួយការមេឃុំលើការងារដូចខាងក្រោម៖

- រៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់មេឃុំ
- គ្រប់គ្រងទិន្នន័យភូមិ និងស្ថិតិ
- សម្របសម្រួលហការជាមួយមន្ទីរ អង្គការសង្គមស៊ីវិលផ្នែកឯកជន និងសប្បុរសជនលើសកម្មភាពអភិវឌ្ឍន៍ឃុំ
- ទទួលបន្ទុកការងារប្រចាំភូមិអូរឧកញ៉ាហេង
- ជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ឃុំ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យរបស់មេឃុំ។

៧ លោក ប៉ុល ជី សមាជិកក្រុមប្រឹក្សាឃុំ មានតួនាទី និងភារកិច្ចជំនួយការជួលមេឃុំលើការងារដូចខាងក្រោម៖

- វាសុខាភិបាល និងសុខភាពសាធារណៈ
- ធម្មការ និងវិចិត្រសិល្បៈ
- នេះជាការជួយសង្គ្រោះប្រជាពលរដ្ឋពេលមានគ្រោះធម្មជាតិឬគ្រោះថ្នាក់ផ្សេងៗ
- ការងារយេនឌ័រ
- ទទួលបន្ទុកការងារប្រចាំភូមិអូរតាប៉ាង និងភូមិអូរចំណារ
- ទទួលបន្ទុកការងារអប់រំ យុវជន កីឡា និងអក្ខរកម្ម
- ការងារទេសចរណ៍ និងការងារបេតិកភណ្ឌរមណីយដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រនានា

ក្រុមប្រឹក្សាឃុំឧញ៉ាហេងត្រូវធ្វើការប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ (មាត្រា២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ)[២] ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចធ្វើការប្រជុំពិសេសដើម្បីធ្វើការពិភាក្សាលើបញ្ហាទាំងឡាយណា ដែលក្រុមប្រឹក្សាបានកំណត់ថាជាកិច្ចការពិសេស ឬកិច្ចការបន្ទាន់ចាំបាច់ ។

កិច្ចប្រជុំពិសេស(៣)ត្រូវប្រារព្ធឡើងក្នុងអំឡុងពេល៣(បី)ថ្ងៃបន្ទាប់ពីប្រធានក្រុមប្រឹក្សាសម្រេចឲ្យមាន ការឲ្យការរៀបចំកិច្ចប្រជុំពិសេសនេះ ឬបន្ទាប់ពីសមាជិកមួយភាគបីយ៉ាងតិចនៃសមាជិកក្រុមប្រឹក្សាសរុបទាំង អស់ស្នើសុំឲ្យរៀបចំកិច្ចប្រជុំពិសេស ។

ការសម្រេច ឬការស្នើសុំឲ្យមានការប្រជុំពិសេសត្រូវបញ្ជាក់ពីមូលហេតុសមស្រប ។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំឧញ៉ាហេង និងគណៈកម្មាធិការជំនួយការត្រូវធ្វើជាសាធារណៈ លើក លែងតែបញ្ហាដូចមានចែងក្នុងប្រការ៩ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ។ ការប្រជុំត្រូវធ្វើឡើងក្នុង សាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសរើសយកទីកន្លែងណា មួយក្នុងឃុំសង្កាត់របស់ខ្លួនដើម្បីប្រជុំ។ ការប្រជុំក្រុមប្រឹក្សាឃុំសង្កាត់នឹងយកជាការបានការ លុះត្រាតែមាន ចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូលចូលរួម។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធ្វើ ការបោះឆ្នោតអនុម័ត(៤)ដោយសម្លេងភាគច្រើនដាច់ខាត (absolute majority) នៃសមាជិកក្រុមប្រឹក្សា ទាំងមូលដើម្បីសម្រេចបញ្ហាណាមួយដូចខាងក្រោមនេះ៖

- អនុម័តលើគម្រោងផែនការអភិវឌ្ឍន៍ឃុំសង្កាត់
- អនុម័តលើគម្រោងថវិកាឃុំសង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗ
- អនុម័តបទបញ្ជាផ្ទៃក្នុង និងដីការឃុំសង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមនុភាព (prevail) ។ ហើយការប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធ្វើឡើងជាសាធារណៈ (in public) និងមាន លក្ខណៈប្រជាធិបតេយ្យ។ ក៏ប៉ុន្តែនៅក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំសង្កាត់អាចប្រជុំជាសម្ងាត់បាន។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់មានសេរីភាពក្នុងការបញ្ចេញមតិ(៥)ក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំសង្កាត់។ ហើយ សមាជិករូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសម្តែង យោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំសង្កាត់បានឡើយ។

---

(២)មាត្រា២១ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

(៣)ប្រការ១ ជំពូកទី១ អំពីកិច្ចប្រជុំ ដីកាស្តីពីបទបញ្ជាឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

(៤)ក្រុមប្រឹក្សា ក្នុងប្រព័ន្ធរដ្ឋបាលមូលដ្ឋាន របស់ Development in Cambodia website ខែកក្កដា ឆ្នាំ២០០៩

(៥) ប្រការ១៦ ដីកា ស្តីពី បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ឃុំសង្កាត់និមួយៗត្រូវមានក្រុមប្រឹក្សាមួយ ហៅថាក្រុមប្រឹក្សាឃុំសង្កាត់ (Commune/Sangkat Council) ដែលជាអង្គការតំណាងឲ្យប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត[៦]ដោយប្រជាពលរដ្ឋនៃឃុំសង្កាត់របស់ខ្លួន ស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ ក្រុមប្រឹក្សានោះត្រូវមានមានអាណត្តិ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំសង្កាត់ថ្មីចូលកាន់តំណែង។ នៅក្នុងតំណាក់កាលអន្តរកាល ក្រុមប្រឹក្សាឃុំសង្កាត់ដែលផុតអាណត្តិមានភារកិច្ចគ្រាន់តែសម្រួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្រុមប្រឹក្សាឃុំសង្កាត់មានសមាជិក[៧]ពី ៥ ទៅ ១១ រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវមានប្រធានម្នាក់ ហៅថាប្រធានក្រុមប្រឹក្សាឃុំសង្កាត់ (Presiding councilor of the Commune/Sangkat Council) ដែលមានភារកិច្ចដូចតទៅនេះ៖

- ធ្វើជាអធិបតេយ្យក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន
- ធានាឲ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់យ៉ាងតិចឲ្យបានមួយដងក្នុងមួយខែ[៨]
- ធានាឲ្យសម័យប្រជុំក្រុមប្រឹក្សាឃុំសង្កាត់[៩]របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំសង្កាត់ និងបទប្បញ្ញត្តិ
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។

## ១.២ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

### ១.២.១ គណៈកម្មការលទ្ធកម្ម

បង្កើតគណៈកម្មការលទ្ធកម្ម[១០]ឃុំអូរខកញ៉ាហេងមានសមាសភាពដូចខាងក្រោមៈ

១ លោក កៅ ឡេង មេឃុំ ជាប្រធាន

២ លោក ហែម សារ៉ាត់ សមាជិកក្រុមប្រឹក្សា ជាសមាជិក

៣ លោក ងួន សំអាត សមាជិកក្រុមប្រឹក្សា ជាសមាជិក

៤ លោក មាស វាសនា ស្មៀនឃុំ ជាលេខាធិការ

គណៈកម្មការលទ្ធកម្មឃុំអូរខកញ៉ាហេងមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

១ ផ្តល់អនុសាសន៍ដល់មេឃុំលើការផ្តល់កិច្ចសន្យា និងបញ្ជាទិញ

២ វាយតម្លៃលើដំណើរការដេញថ្លៃរបស់អ្នកទទួលការ និងអ្នកផ្គត់ផ្គង់

៣ រៀបចំឯកសារដេញថ្លៃ និងផ្តល់យោបល់ដល់មេឃុំពីដំណើរការដេញថ្លៃ

---

[៦]ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

[៧]មាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[៨]មាតា២១ នៃច្បាប់ស្តី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[៩]មាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

[១០]សេចក្តីសម្រេចបង្កើតគណៈកម្មការលទ្ធកម្ម តាមបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាអូរខកញ៉ាហេង

**១.២.២ គណៈកម្មាធិការគ្រប់គ្រងគម្រោងមូលនិធិឃុំ**

លោកមេឃុំជាប្រធាន លោក ជំទប់ទី១ ជាអនុប្រធាន ក្រៅពីនោះជាសមាជិកទាំងអស់។ តួនាទីរបស់គណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិ[១១]ឃុំ សង្កាត់មានដូចខាងក្រោមៈ

១- រៀបចំគម្រោង

២- ឯកភាពនៅលើគ្រោងការគម្រោង

៣- ប្រមូលទុនចូលរួមរបស់មូលដ្ឋាន

៤- តាមដានការងាររបស់អ្នកទទួលការ

៣- ប្រមូលទុនចូលរួមរបស់មូលដ្ឋាន

៤- តាមដានការងាររបស់អ្នកទទួលការ

៥- ពិនិត្យរបាយការណ៍រីកចម្រើនរបស់កិច្ចសន្យា ដែលរៀបចំអ្នកត្រួតពិនិត្យបច្ចេកទេសមុន ធ្វើការទូទាត់នីមួយៗទៅឱ្យអ្នកទទួលការ ។

**១.២.៣ គណៈកម្មាធិការស្ត្រីនិងកុមារ គ ក ន ក**

គណៈកម្មាធិការស្ត្រីនិងកុមារ[១២] ទទួលបន្ទុកទៅលើកិច្ចការនារីនិងកុមារមានសមាសភាពចំនួន ១២ រូប ដឹកនាំដោយប្រធាន ១រូប ជាមេឃុំ និងអនុប្រធាន ១រូប ជាជំទប់ទី២ និងមានសមាជិកចំនួន ១០រូបទៀត ព្រោះមានជនបង្គោលចំនួន ១ រូបនាយប៉ុស្តិ៍ចំនួន ១ រូបនាយកសាលាបឋមសិក្សាចំនួន ២ រូបបុគ្គលិកមណ្ឌលសុខភាពចំនួន ១ រូបនិងមេភូមិចំនួន ៥ រូបជាសមាជិក។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជូនក្រុមប្រឹក្សាឃុំអនុម័ត។
- ផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាឃុំ និងមេឃុំចំពោះការងារពាក់ព័ន្ធនឹងកិច្ចការនារី និងកុមារនៅឃុំអូរឧកញ៉ាហេង។
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធនឹងសិទ្ធិនារីសិទ្ធិកុមារនៅក្នុងឃុំអូរឧកញ៉ាហេង និងបំផុសចលនាសហគមន៍នៅលើវិស័យសុខភាពអប់រំកិច្ចការការពារអភិវឌ្ឍន៍កុមារព្រមទាំងការចុះបញ្ជីអគ្រានុកូលដ្ឋានជូនទារកនិងកុមារ។
- ទាក់ទាញការគាំទ្រដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍមូលដ្ឋាននៅឃុំ។
- បង្កើន និងពង្រឹងនូវការប្រាស័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយនារី និងកុមារនៅក្នុងឃុំរបស់ខ្លួន។
- ជួយក្រុមប្រឹក្សាឃុំក្នុងការប្រមូលវិភាគព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងបញ្ហានៃតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគ។

[១១]សេចក្តីសម្រេចបង្កើនគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិ តាមបញ្ជផ្ទៃក្នុងរបស់ក្រុមប្រឹក្សាអូរឧកញ៉ាហេង

[១២]សេចក្តីសម្រេចបង្កើនគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិ តាមបញ្ជផ្ទៃក្នុងរបស់ក្រុមប្រឹក្សាអូរឧកញ៉ាហេង

- ចូលរួមអនុវត្តពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំពាក់ព័ន្ធនឹងស្ថានភាពនារីនិងកុមារ
- តាំងដើមស្ថានភាពនារី និងកុមារនៅក្នុងឃុំ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍ឃុំ។
- មេឃុំដែលជាប្រធានគណៈកម្មាធិការត្រូវមានការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំរបស់ខ្លួន
- គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកដល់សេវាកម្មនានាផ្នែកសង្គមកិច្ចអ្នកស្ម័គ្រចិត្តភូមិ និងសហគមន៍ក្នុងឃុំដើម្បីបំពេញតួនាទីភារកិច្ចខាងលើអោយមានប្រសិទ្ធភាព។

**១.២.៤ គណៈកម្មាធិការកសាងផែនការ និងថវិកា**

គណៈកម្មាធិការកសាងផែនការ[១៣] និងថវិកាមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- ត្រូវជួយមេឃុំក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ[១៤] កម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ ។
- ត្រូវអនុវត្តវិធីសាស្ត្រកសាងផែនការអភិវឌ្ឍឃុំនូវកម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំតាមអភិក្រម មានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ។

បង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា ដែលមានសមាសភាពដូចខាងក្រោមៈ

1. លោក កៅ ឡេង មេឃុំ ជាប្រធាន គ ផ ថ
2. លោក ហែម សារ៉ាត់ ជំទប់ទី១ ជាសមាជិក
3. លោក ងួន សំអាត ជំទប់ទី២ ជាសមាជិក
4. លោក ញ៉ែម វណ្ណា សមាជិកក្រុមប្រឹក្សា ជាសមាជិក
5. លោកស្រី ទាវ ណៃហ៊ាង សមាជិកក្រុមប្រឹក្សា ជាសមាជិក
6. លោក សុខចាន់សីហា សមាជិកក្រុមប្រឹក្សា ជាសមាជិក
7. លោក ខឹម ចេង សមាជិកក្រុមប្រឹក្សា ជាសមាជិក
8. លោក មាស ប៊ុនយុទ្ធ មេភូមិបត់គគីរ ជាសមាជិក
9. លោក អ៊ឹប វ៉ាន់ អនុភូមិបត់គគីរ ជាសមាជិក
10. លោកស្រី សេង គឹមហុង សមាជិកភូមិបត់គគីរ ជាសមាជិក
11. លោក ម៉ម តារា មេភូមិអូរចំណារ ជាសមាជិក
12. លោក ដៃ ផាង អនុភូមិអូរចំណារ ជាសមាជិក
13. លោកស្រី ម៉ម កល្យាណ សមាជិកភូមិអូរចំណារ ជាសមាជិក
14. លោក ឈន វណ្ណា មេភូមិអូរតាប៉ាង ជាសមាជិក
15. លោក សរ សារឿន អនុភូមិអូរតាប៉ាង ជាសមាជិក

[១៣]សេចក្តីសម្រេចបង្កើនគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិ តាមបញ្ញត្តិក្នុងរបស់ក្រុមប្រឹក្សាអូរឧកញ៉ាហេង

[១៤]គោលគំនិតនៃការអភិវឌ្ឍឃុំ សង្កាត់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

16. លោកស្រី ចាន់ សុវីយ៉ា សមាជិកភូមិអូរតាប៉ាង ជាសមាជិក
17. លោក ឯក ជិន មេភូមិអូរតាសេក ជាសមាជិក
18. លោក អ៊ូ តាប់ អនុភូមិអូរតាសេក ជាសមាជិក
19. លោកស្រី ឯក រីន សមាជិកភូមិអូរតាសេក ជាសមាជិក
20. លោក គុង បៀវ៍ មេភូមិអូរឧកញ៉ាហេង ជាសមាជិក
21. លោក ហាយ សំបូរ អនុភូមិអូរឧកញ៉ាហេង ជាសមាជិក
22. លោក សឿ គឹមសាន សមាជិកភូមិអូរឧកញ៉ាហេង ជាសមាជិក
23. លោក មាស វាសនា ស្មៀនឃុំ ជាសមាជិក

### ១.២.៥ គណៈកម្មាធិការមណ្ឌលសុខភាព

គណៈកម្មាធិការមណ្ឌលសុខភាព ជាគណៈកម្មាធិការមួយដែលបង្កើតឡើងដើម្បីជួយពង្រឹងផ្នែកសុខាភិបាលនៅក្នុងឃុំ ដែលមានសមាសភាពដូចខាងក្រោម៖

១ លោក កៅ ឡេង មេឃុំ ជាប្រធាន

២ លោក ហែម សារ៉ាត់ សមាជិកក្រុមប្រឹក្សា ជាសមាជិក

៣ លោក ងួន សំអាត សមាជិកក្រុមប្រឹក្សា ជាសមាជិក

៤ លោកស្រី ទាវ ណៃហ៊ាង សមាជិកក្រុមប្រឹក្សា ជាសមាជិក

៥ លោក ប៉ុល ជី សមាជិកក្រុមប្រឹក្សា ជាសមាជិក

៦ លោក មាស វាសនា ស្មៀនឃុំ ជាសមាជិក

គណៈកម្មាធិការមណ្ឌលសុខភាព តួនាទី និងភារកិច្ចតាមដានការងារសុខាភិបាល និងសុខភាពសាធារណៈរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ចាត់វិធានការជួយសង្គ្រោះពេលប្រជាជនមានគ្រោះថ្នាក់ផ្សេងៗ ផ្តល់ជាជំនួយនិងសម្ភារៈសម្រាប់មណ្ឌលសុខភាព និងតាមដានស្ថានភាពដោយផ្តល់វ៉ាក់សាំងការពារជំងឺផ្សេងៗដល់ ស្ត្រី កុមារ ដែលងាយរងគ្រោះ។

## ១.៣ មេឃុំ

មេឃុំ ចៅសង្កាត់គឺជាប្រធានក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំសង្កាត់ របស់ខ្លួនផងហើយក៏ជាអ្នកដឹកនាំបញ្ជាប្រតិបត្តិដោយរួមមានកិច្ចការរដ្ឋបាលឃុំ សង្កាត់ ផងដែរដោយសារគេមិនបានវែកញែកឲ្យដាច់រវាងអំណាចប្រតិបត្តិនិងអំណាចបញ្ញត្តិ[១៥]ដែលមាននៅក្នុងថ្នាក់រដ្ឋបាលឃុំ សង្កាត់ ។ ក្នុងតួនាទីនេះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាអធិបតីនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ធានាឲ្យមានការប្រជុំរបស់ក្រុមប្រឹក្សាយ៉ាងតិចម្តងក្នុងមួយខែជាអ្នកការពារបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ។

[១៥]សិទអំណាចរបស់ក្រុមប្រឹក្សាអ្នកដឹកនាំអង្គប្រជុំក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំអូរឧកញ៉ាហេង

មេឃុំចៅសង្កាត់ គឺជាអ្នកប្រតិបត្តិតាមការប្រគល់អំណាចពីក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា នេះ ។ មេឃុំ ចៅសង្កាត់ក៏មានភារកិច្ចទទួលខុសត្រូវចំពោះម្ចាស់សន្លឹកឆ្នោតជាពិសេសចំពោះគោលនយោបាយបក្សដែលមេឃុំ ចៅសង្កាត់ក៏មិនអាចល្មើសបានដែរ ។មេឃុំ ត្រូវមានជំនួយការ ២រូប ចាំបាច់គឺ ជំទប់ទី១ និងជំទប់ទី២។

**១.៣.១ ជំទប់ទី១**

- ទទួលធ្វើជាជួយមេឃុំ លើសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មេឃុំអាចប្រគល់ ឬភារកិច្ចបន្ថែមដល់ជំនប់ទី១
- បំពេញការងារជាមេឃុំ ករណីមេឃុំអវត្តមាន។

**១.៣.២ ជំទប់ទី២**

- ជួយមេឃុំក្នុងការងាររដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ សណ្តាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន
- មេឃុំអាចប្រគល់ការងារបន្ថែមដល់ជំនប់ទី២
- ពំពេញការងារជាមេឃុំ ករណីមេឃុំអវត្តមាន។

**១.៣.៣ ស្មៀន**

ក្រសួងមហាផ្ទៃបានតែងតាំង[១៦] លោកមាស វាសនា ជាមន្ត្រីស្មៀនឃុំអូរឧកញ្ញាហេងក្នុងឆ្នាំ២០០១ និងត្រូវបំពេញការងារដូចខាងក្រោមៈ

- ជាគោលការណ៍ត្រូវបំពេញការងារជាមន្ត្រីជំនួយការឃុំតាមការណែនាំមេឃុំ
- មុនពេលមានក្រុមប្រឹក្សាឃុំ ដែលកើតចេញពីការបោះឆ្នោតមន្ត្រីស្មៀនត្រូវជួយមេឃុំ បច្ចុប្បន្នលើការងារដូចខាងក្រោមៈ
    - ប្រចាំការក្នុងសាលាឃុំរៀងរាល់ម៉ោងធ្វើការ ដើម្បីទទួលសំណើរសំណូមពរផ្សេងៗពីប្រជាពលរដ្ឋ ឬអាជ្ញាធរនានា ដើម្បីលើកយោបល់ អំពីគោលការណ៍ វិធានការ ជូនមេឃុំពិនិត្យសម្រេច។
    - រៀបចំសាលាឃុំឲ្យមានអនាម័យសណ្តាប់ធ្នាប់តាមការសម្រេចរបស់មេឃុំ។
    - ចំពោះឃុំសង្កាត់ណាដែលមិនទាន់មានសាលាសង្កាត់ ឬសាលាឃុំ ស្មៀនត្រូវរាយការណ៍ជូនចៅសង្កាត់ ឬមេឃុំដើម្បីលើកយោបល់ជូនសាលាស្រុក ឬសាលាខណ្ឌ។ ការប្រចាំការរបស់ស្មៀនឃុំត្រូវធ្វើតាមការសម្រេចពីមេឃុំបន្ទាប់ពីមានយោបល់ឯកភាពពីអភិបាលខណ្ឌសាមី។
    - រៀបចំឯកសារលិខិតស្នាមនានាក្នុងសង្កាត់ និងរៀបចំបញ្ជីលិខិតស្នាមទាំងនោះឲ្យបានត្រឹមត្រូវ។
    - ប្រមូលព័ត៌មានស្រង់ស្ថិតិប្រជាពលរដ្ឋក្នុងសង្កាត់របស់ខ្លួនឱ្យបានជាប្រចាំ។

---

[១៦]ប្រការ២ ដីកាស្តីពីការតែងតាំង និងប្រគល់តួនាទីជូនមន្ត្រីស្មៀនឃុំសង្កាត់ របស់អភិបាលក្រុងព្រះសីហនុ ក្រសួងមហាផ្ទៃ លេខ ០៨៥ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១

- ធ្វើបញ្ជីស្ថិតិទ្រព្យសម្ភារៈជាអចលនទ្រព្យ និងចលនទ្រព្យដែលកំពុងគ្រប់គ្រងដោយសង្កាត់។
- រៀបចំរបាយការណ៍អំពីសភាពការណ៍នានាប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំក្នុងសង្កាត់ដាក់ជូនចៅសង្កាត់ពិនិត្យសម្រេច និងផ្ញើជូនសាលាខណ្ឌតាមគោលការណ៍កំណត់
- បើមានសំណូមពរពីកម្មវិធី ឬអង្គការនានាដែលមានបំណងប្រើប្រាស់មន្ត្រីស្មៀនសង្កាត់ឲ្យជួយចៅសង្កាត់ ឬគណៈកម្មាធិការអភិវឌ្ឍសង្កាត់ត្រូវបង្កលក្ខណៈសម្បត្តិឱ្យមន្ត្រីស្មៀនបានចូលរួមតាមការស្នើសុំ
- រួមសហការជាមួយមន្ត្រីជំនួយការសង្កាត់ជួយចៅសង្កាត់លើការងារអត្រានុកូលដ្ឋាន
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីចៅសង្កាត់នៃសង្កាត់ដែលខ្លួនកំពុងបំពេញការងារ
- ត្រៀមរៀបរបាយការណ៍បញ្ជីស្នាមឯកសារបញ្ជីស្ថិតិទ្រព្យសម្បត្តិ និងឯកសារលិខិតស្នាមផ្សេងជូនចៅសង្កាត់ដើម្បីផ្ទេរប្រគល់ជូនក្រុមប្រឹក្សាសង្កាត់ថ្មី តាមគោលការណ៍ច្បាប់
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីចៅសង្កាត់នៃសង្កាត់ដែលខ្លួនកំពុងបំពេញការងារ
- ក្រោយពីការបោះឆ្នោត និងការតែងតាំងចៅសង្កាត់លេខជាប់ឆ្នោតឱ្យចូលកាន់មុខតំណែងរួចហើយមន្ត្រីស្មៀនសង្កាត់ទាំងអស់នឹងក្លាយជាស្មៀនសង្កាត់ដោយស្វ័យប្រវត្តិបើពុំមានកំហុសឆ្គងណាមួយទេ។

**១.៣.៤ មេភូមិ**

ក្រុមប្រឹក្សាឃុំសង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់ៗសម្រាប់មេភូមិនីមួយៗក្នុងឃុំរបស់ខ្លួន។ មេភូមិ មានតួនាទីដូចខាងក្រោមៈ

- ជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ
- ជាទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំសង្កាត់
- ទទួលការណែនាំធ្វើកិច្ចសហការប្រតិបត្តិជាមួយក្រុមប្រឹក្សាឃុំសង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំនាននារបស់ខ្លួន នៅពេលដែលក្នុងប្រឹក្សាឃុំសង្កាត់ដើម្បីផ្តល់យោបល់អំពីកិច្ចពាក់ព័ន្ធនៅក្នុងឃុំរបស់ខ្លួន
- ធ្វើសេចក្តីរាយការបញ្ហាដែលពាក់ព័ន្ធនិងភូមិរបស់ខ្លួន ដើម្បីដាក់ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំសង្កាត់
- ផ្តល់ព័ត៌មានដែលពាក់ព័ន្ធជូនប្រជាពលរដ្ឋរបស់ខ្លួន
- ទទួលខុសត្រូវអនុវត្តផែនការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន។

## ១.៤ កិច្ចការរដ្ឋបាលឃុំ

### ក. លិខិតរដ្ឋបាលឃុំ

ប្រភេទលិខិតរដ្ឋបាលឃុំ[១៧] សង្កាត់ ដែលបានប្រើប្រាស់នៅក្នុងឃុំអូរឧកញ៉ាហេងមានដូចខាងក្រោមៈ

- ដីកាឃុំ សង្កាត់
- សេចក្តីសម្រេចឃុំ សង្កាត់
- លិខិតស្នើ
- សេចក្តីជូនដំណឹង
- លិខិតអញ្ជើញ
- លិខិតបញ្ជាបេសកកម្ម
- របាយការណ៍
- កំណត់ហេតុ
- លិខិតផ្ទេរសិទ្ធ
- ដីការអម ។

ការងាររបៀបក្នុងឃុំអូរឧកញ៉ាហេងមាន លិខិតចូល និងលិខិតចេញដែលតែងតែប្រើប្រាស់ជារៀងរាល់ខែ។

ការគ្រប់គ្រងបុគ្គលិកនៅក្នុងឃុំអូរឧកញ៉ាហេង មានការគ្រប់គ្រងដូចខាងក្រោមៈ

- ការរៀបចំបញ្ជីគ្រប់គ្រងបុគ្គលិកឃុំ សង្កាត់
- គោលការណ៍ផ្តល់ការងារ
- នីតិវិធីនៃការជ្រើសរើសបុគ្គលិក
- ការជ្រើសរើសតាមរយៈប្រវត្តិរូបសង្ខេប
- ការប្រឡងជ្រើសរើស
- កិច្ចសន្យាផ្តល់ការងារសម្រាប់បុគ្គលិក
- រយៈពេលសាកល្បង
- ប្រាក់ឧបត្ថម្ភ ការទូទាត់ប្រាក់ឧបត្ថម្ភ និងការបុរេប្រទានប្រាក់ឧបត្ថម្ភ
- ថិរវេលាធ្វើការ
- ការងារលើសម៉ោង
- ការឈប់សម្រាកផ្លូវការ ការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកពិសេស
- វិធានការដាក់វិន័យ ការបញ្ចប់កិច្ចសន្យា

---

[១៧] សៀវភៅណែនាំ កិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រសួងមហាផ្ទៃ ឆ្នាំ២០០៥

- ការលើកសសើរ
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក។

**ការគ្រប់គ្រងសាលាឃុំ សង្កាត់៖**

- ការគ្របគ្រង់សម្ភារបរិក្ខាឃុំ សង្កាត់
- ការធ្វើដំណើរ
- ការគ្រប់គ្រងសម្ភារការិយាល័យ
- ការរក្សាសុវត្ថិភាពនៃកូនសោរ

**ការគ្រប់គ្រងឯកសារ៖**

- ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ
- ប្រភេទឯកសារ
- ការប្រើប្រាស់ឯកសារ
- បច្ចេកទេសក្នុងការគ្រប់គ្រងឯកសារ
- ការគ្រប់គ្រងឯកសារឃុំ សង្កាត់សម្ភារចាំបាច់សម្រប់ទុកដាក់ និងថែរក្សារឃុំ សង្កាត់

រចនាសម្ព័ន្ធរដ្ឋបាលឃុំអូរឧកញ៉ាហេងអាណត្តិទី៤



# ជំពូកទី ២
# ការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តការងាររបស់ឃុំអូរឧកញ៉ាហេង

## ២.១ ស្ថានភាពទូទៅនៃឃុំអូរឧកញ៉ាហេង

ឃុំអូរឧកញ៉ាហេងជាឃុំមួយក្នុងចំណោមឃុំទាំង ១៤ ស្ថិតក្នុងស្រុកព្រៃនប់ខេត្តព្រះសីហនុឃុំនេះមានផ្លូវលំអភិវឌ្ឍន៍ក្រាលក្រួសក្រហមតភ្ជាប់ពីផ្លូវជាតិលេខ ៤ ទៅភូមិកោះខ្យងឆ្នេរសមុទ្រការធ្វើដំណើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយមានភាពងាយស្រួលដោយភូមិនីមួយៗស្ថិតនៅជាប់នឹងផ្លូវអភិវឌ្ឍន៍ និងមានផ្លូវលំតូចតភ្ជាប់ទៅគ្រប់ភូមិទាំងអស់ដែលមានយានយន្តអាចចេញចូលបានគ្រប់រដូវកាលឃុំអូរឧកញ៉ាហេងមានភូមិចំណុះចំនួន ៥ ភូមិដឹកនាំគ្រប់គ្រងដោយ ព្រមទាំងមេឃុំ សមាជិកក្រុមប្រឹក្សាប្រាំមួយនាក់និងម្នាក់ជាស្ត្រី។

### ២.១.១ ស្ថានភាពភូមិសាស្ត្រ

សាលាឃុំអូរឧកញ៉ាហេងមានទីតាំង[១៨]ស្ថិតនៅប៉ែកខាងលិចឈៀងងខាងត្បូងនៃសាលាស្រុកព្រៃនប់ចម្ងាយប្រមាណ ១៥ គីឡូម៉ែត្រពីទីរួមស្រុក នឹងចំងាយប្រមាណ ២៧ គីឡូម៉ែត្រពីទីរួមខេត្តព្រះសីហនុ។ ឃុំនេះមានព្រំប្រទល់ខាងជើងទល់នឹងឃុំព្រៃនប់ ខាងកើតទល់នឹងឃុំបឹងតាព្រហ្ម ខាងលិចទល់នឹងឃុំរាម (ព្រែកទឹកសាប) និងខាងត្បូងទល់នឹងឃុំរាម (សមុទ្រ) ។ ឃុំអូរឧកញ៉ាហេងមានចំនួន ៥ ក្នុងភូមិជាចំណុះភូមិបត់គគីរ ភូមិអូរចំណារ ភូមិអូរតាប៉ាង ភូមិអូរតាសេក និងភូមិអូរឧកញ៉ាហេង។ ប្រជាជននៅក្នុងឃុំមានចំនួន ២០៣៣ គ្រួសារ ដែលមានចំនួនសរុបចំនួន ៩៩៧៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ៤៨៩៦ នាក់។ ទីតាំងភូមិសាស្ត្រឃុំ[១៩]ជាពីរផ្នែកមានផ្ទៃដីគោក និងផ្ទៃដីជាប់ព្រែកដៃសមុទ្រ និងស្ថិតនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុរាមដែលមានផ្ទៃដីសរុប ១០.៣១៥ហិតាដែលចែកចេញជាៈ ផ្ទៃដីលំនៅដ្ឋានចំនួន ៣៤៩,៤៤ហិតា ផ្ទៃដីកសិកម្ម២.៤៩២,៧៤ហិតា ( ក្នុងនោះផ្ទៃដីអាចធ្វើស្រែវស្សាបានចំនួន ៩៧០ហិតា ផ្ទៃដីដាំដំណាំរយៈពេលខ្លីចំនួន ៣០០ ហិតា ផ្ទៃដីដាំដំណាំរយៈពេលវែងចំនួន ១០០០ហិតា) ផ្ទៃដីផ្សេងៗចំនួន ១.៣២៦,៥៨ហិតា។

ចំពោះព្រំប្រទល់រដ្ឋបាលនៅមិនទាន់មានការឯកភាពគ្នានៅឡើយទេដោយមានភាពខុសគ្នារវាងព្រំប្រទល់ក្នុងផែនទីនឹងព្រំប្រទល់[២០]ដែលគ្រប់គ្រងជាក់ស្តែងដោយសាលាឃុំ ដូចជានៅផ្នែកខាងជើងនៃឃុំអូរឧកញ៉ាហេងគឺជាការគ្រប់គ្រងរបស់ឃុំព្រៃនប់បានរំលោភចូលមកក្នុងឃុំអូរឧកញ៉ាហេងចំនួនចម្ងាយប្រហែល ០១ គីឡូម៉ែត្រ ហើយនៅផ្នែកខាងកើតនៃឃុំអូរឧកញ៉ាហេងវិញគឺការគ្រប់គ្រងរបស់ឃុំអូរឧកញ៉ាហេងបានរំលោភចូលក្នុងឃុំបឹងតាព្រហ្មចម្ងាយប្រហែល ០១ គីឡូម៉ែត្រ ដោយគ្រប់គ្រងរហូតដល់មាត់សមុទ្រតែម្តង។

---

[១៨]ផែនការប្រើប្រាស់ដីឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

[១៩]ព័ត៌មានស្ថានភាព ស្តីពី ពិន្ទុវិស័យតាមបណ្តាឃុំ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឆ្នាំ២០១៥

[២០]ឯកសារ និងផែនទីគំរបព្រៃឈើ ឆ្នាំ២០១៥

សេចក្តីសង្ខេបទិន្នន័យចម្បង[២៧]របស់ឃុំអូរឧកញ៉ាហេង

| លៈរ | បរិយាកាស | ឆ្នាំ២០១៨ | ២០១៩ |
|---|---|---|---|
| ព័ត៌មានទូទៅ | | | |
| ១ | ផ្ទៃដីឃុំ (គ.ម²) | ៩៧៧០ គ.ម² | ៩៧៧០ គ.ម² |
| ២ | ចំនួនភូមិ | ៥ភូមិ | ៥ភូមិ |
| ៣ | ចំនួនគ្រួសារ | ១៦៨៨គ្រួសារ | ១៨១២គ្រួសារ |
| ៤ | %មេគ្រួសារជាស្ត្រី | ១៩,៥០% | ១៨,៨០% |
| ៥ | ចំណួនប្រជាជនសរុប | ៩០០៦នាក់ | ៩០៥៧នាក់ |
| ៦ | ចំនួនស្រី | ៤៥៥៩នាក់ | ៤៥៣០នាក់ |
| ៧ | ចំនួនប្រុស | ៤៤៤៧នាក់ | ៤៥២៧នាក់ |
| ៨ | % អ្នកមានអាយុពី០-១៧ឆ្នាំ | ៤១% | ៤១,៣០% |

| លៈរ | បរិយាកាស | ២០១៨ | ២០១៩ |
|---|---|---|---|
| ៩ | %អ្នកមានអាយុពី ១៨-៦០ឆ្នាំ | ៥៣,៧០% | ៥៣,៤០ |
| ១០ | %អ្នកមានអាយុពី ៦១ឆ្នាំឡើង | ៥,៣០% | ៥,៣០ |
| ១១ | កំណើនប្រជាជនប្រចាំឆ្នាំ(%) | ០,២០% | ០,៦០ |
| ១២ | អត្រាភាពក្រីក្រ (%) | ១៣,៧១% | ១២,៣៩ |
| ១៣ | %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | ៦៤,៩០% | ៥៦,៥០ |
| ១៤ | %អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ០,១០% | ០,១០ |
| ១៥ | %អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ៣៥,១០% | ៤៣,៤០ |
| ១៦ | %មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | ២,៦០% | ៣ |
| ១៧ | %មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | ១,២០% | ១,២០ |
| ១៨ | %ក្នុងផ្ទះមានអគ្គិសនីប្រើប្រាស់ | ៧៧% | ៩០,២០ |
| អប់រំ | | | |
| ១៩ | %កុមារអាយុ៣-៥ ឆ្នាំបានចូលរៀន | ៤៦,៥០% | ៣៩,៥០ |
| ២០ | %កុមារអាយុ ៦ឆ្នាំបានចូលរៀន | ៩៦,៧០% | ៩១,២០ |
| ២១ | %កុមារអាយុ ៦-១១ឆ្នាំបានចូលរៀន | ៩៣,១០% | ៨៨ |
| ២២ | %កុមារអាយុ ១២-១៤ឆ្នាំបានចូលរៀន | ៧៩,៧០% | ៨៥,៣០ |
| ២៣ | %អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | ៩៩,៥០% | ៩៩,៥០ |
| ២៤ | %អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | ៩៨,២០% | ៩៨,២០ |

| | | | |
|---|---|---|---|
| សុខភាព | | | |
| ២៥ | ចំនួនមណ្ឌលសុខភាព | ១ | ១ |
| ២៦ | %ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | ១00% | ១00 |
| ២៧ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល (0-១ខែ) ក្នុងមួយកំណើន | 0 | 0 |
| ២៨ | អត្រាស្លាប់របស់មាតាក្រោយពេលកើត (0-១ ខែ) ក្នុងមួយកំណើន | 0 | 0 |
| ២៩ | %កុមារអាយុពី ៩-១២ខែបានចាក់ថ្នាំ បង្ការគ្រប់ចំនួន | ១00 | ១00 |
| ៣0 | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | ១៦គ្រួសារ | ១៦ |
| ភាពងាយរងគ្រោះ | | | |
| ៣១ | ចំនួនជនពិការ | ១១៥នាក់ | ៨៩ |
| ៣២ | %ជនពិការអាយុ១៨ឆ្នាំឡើងមិនអាំចរកចំណូល | ១៥,២0% | ១៧,៧0 |
| ៣៣ | ចំនួនកុមាកំព្រាដែលឪពុកម្តាយស្លាប់ដោយជំងឺអេស៍ | ១៣នាក់ | ១៣ |
| ៣៤ | ចំនួនចាស់ជរាគ្មានទីពឹង (អាយុ៦១ឡើង) | ២នាក់ | ២ |
| ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុ | | | |
| ៣៥ | ចំនួនគ្រួសារដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់ព្យុះ | 0 | ២ |
| ៣៦ | ចំនួនគ្រួសារដែលរងគ្រោះដោយសារទឹកជំនន់ | 0 | 0 |
| ៣៧ | ចំនួនគ្រួសារដែលរងគ្រោះដោយសាររាំងស្ងួត | 0 | 0 |
| ៣៨ | %គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 0 | 0 |
| ៣៩ | %ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | ៤១,៤0% | ៥៣,១0 |
| ក្នុងនោះ | %ចំនួនគ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | 0% | ២,៤៣ |
| | %ចំនួនគ្រួសារមានទឹកអណ្តូងស្នប់/អណ្តូងចំរុះ | ១៧,២៩% | ២៣,២៣ |
| | %គ្រួសារប្រើទឹកអណ្តូងជីកមានការពារ | ២៤,0៥% | ២៤,៤៨ |
| | %គ្រួសារប្រើទឹកភ្លៀងមានការពារ | 0% | 0 |
| ៤0 | %គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៤៦% | ៤៩,៣0 |

| | | | |
|---|---|---|---|
| រដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | |
| ៤១ | %កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | ៩១,៥០% | ៩៤,២០ |
| ៤២ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | ៩គ្រួសារ | ៤ |
| ៤៣ | សរុបចំនួនជនរងគ្រោះដោយការចាប់រំលោភ | ០ | ១ |
| ៤៤ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | ១ | ៣ |
| ៤៥ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ០ | ០ |
| ៤៦ | ចំនួនគ្រួសារមានសមជិកប្រើប្រាស់គ្រឿងញៀន | ៤គ្រួសារ | ៥ |

តារាងស្ថិតិប្រជាពលរដ្ឋ[២២] ប្រចាំឆ្នាំ២០១៩

ចំនួនភូមិ៥ភូមិ ចំនួនគ្រួសារសរុប...១៨១២...គ្រួសារចំនួនបជាពលរដ្ឋសរុប៩០៩១...នាក់ក្នុងនោះស្ត្រីចំនួន ៤៥៨១នាក់ ចំនួនប្រជាពលរដ្ឋខ្មែរអាយុ១៨ឆ្នាំឡើងចំនួន៥២២៤...នាក់ក្នុងនោះស្ត្រី២៦៧០...នាក់

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ប្រជាពលរដ្ឋទូទៅ | | | | | | ប្រជាពលរដ្ឋ១៨ ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្តោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្តោះអាសន្ន | | | |
| | | សរុប | អចិន្ត្រៃយ៍ | ប.អាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ប់តគីរ | ៦០០ | ៥៩៨ | ០២ | ២៩៣១ | ១៤៨៧ | ២៩២៨ | ១៤៧៩ | ០៣ | ០១ | ១៩១២ | ៩៦០ | ១៩១២ | ៩៦០ | ០០ | ០០ | ០០ | ០០ |
| ២ | អូរចំណា រ | ២១៦ | ២១២ | ០៤ | ១០០៦ | ៥៣៤ | ៩៨៩ | ៥២៦ | ១៧ | ០៨ | ៦៤៩ | ៣៥៨ | ៦៤៩ | ៣៥៨ | ០០ | ០០ | ០០ | ០០ |
| ៣ | អូរតា ហង | ៥១២ | ៥០៩ | ០៣ | ២៤៨២ | ១២៣៦ | ២៤៧០ | ១២២៨ | ១២ | ០៦ | ១៦៤៨ | ៨៤៣ | ១៦៤៨ | ៨៤៣ | ០០ | ០០ | ០០ | ០០ |
| ៤ | អូរតា ស ក | ៨៦ | ៨៦ | ០០ | ៤៨១ | ២៤១ | ៤៨១ | ២៤១ | ០០ | ០០ | ៣១១ | ១៦២ | ៣១១ | ១៦២ | ០០ | ០០ | ០០ | ០០ |
| ៥ | អូរឧក៉ញា ហ ង | ៤០៥ | ៣៩៨ | ០៧ | ២១៩១ | ១០៨៣ | ២១៥៨ | ១០៧២ | ៣៣ | ១១ | ១១៥៦ | ៥៩២ | ១១៥៦ | ៥៩២ | ០០ | ០០ | ០០ | ០០ |
| សរុប | | ១៨១២ | ១៧៩៥ | ១៦ | ៩០៩១ | ៤៥៨១ | ៨៧៦៧ | ៤៤២៩ | ៥៥ | ២៦ | ៥២២៤ | ២៦៧០ | ៥២២៤ | ២៦៧០ | ០០ | ០០ | ០០ | ០០ |

## ២.១.២ ស្ថានភាពបច្ចុប្បន្ននិងបញ្ហាប្រឈម

### ២.១.២.១ ស្ថានភាពសេដ្ឋកិច្ច

ឃុំមានប្រភពសក្តានុពលជាច្រើនអំណោយផលបម្រើឲ្យផ្នែកសេដ្ឋកិច្ចដោយទីតាំងភូមិសាស្ត្រស្ថិតនៅជាប់និងតំបន់សមុទ្រដែលមានផ្ទៃដីអភិវឌ្ឍន៍កសិកម្ម (ដីស្រែចំការដំណាំនិងតំបន់វារីវប្បកម្មសមុទ្រនិងតំបន់នេសាទតំបន់អភិរក្សព្រៃកោងកាងជម្រកមច្ឆជាតិ) តំបន់អភិវឌ្ឍន៍ទេសចរណ៍ (រមណីយដ្ឋានធម្មជាតិឧទ្យានជាតិរាម) តំបន់ឧស្សាហកម្ម (រោង-ចក្រ សហគ្រាស) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ល។ សក្តាហ៍នោះពុលទាំងនោះជាកត្តាសំខាន់បម្រើដល់ការអភិវឌ្ឍន៍ឃុំអូរឧកញ៉ាហេង។

មនុស្សអាយុ ១៨ ឆ្នាំឡើងមានមុខរបរចម្បងសរុបមានអត្រា ៩៥,៩០% ប្រុសមានអត្រា ៨៩% ស្ត្រីមានអត្រា ៨៥,៦០%។

ភាពក្រីក្រស្ថិតនៅក្នុងអត្រាកម្រិត[២៣] ១២,៣៩% នៃចំនួនគ្រួសារសរុបសំខាន់ៗដែលបណ្តាលអោយអត្រាភាពក្រីក្រក្នុងឃុំមានកម្រិតខ្ពស់បច្ចុប្បន្នគ្រួសារប្រកបរបរកសិកម្មត្រូវថយចុះទិន្នផលកសិផលកសិកម្ម

[២១]តារាងសេចក្តីសង្ខេបទិន្នន័យចម្បងរបស់ឃុំអូរឧកញ៉ាហេង ប្រភពទិន្នន័យ GIS ស្តីពីស្ថានភាពឃុំអូរឧកញ៉ាហេង

[២២]តារាងស្ថិតិប្រជាពលរដ្ឋ ប្រចាំឆ្នាំ២០១៩ ស្ថិតិថ្នាក់ឃុំ

[២៣]អត្រាភាពក្រីក្រ ប្រភពទិន្នន័យ GIS ស្តីពីស្ថានភាពឃុំអូរឧកញ៉ាហេង

ទទួលបានតិចនិងមានតម្លៃទាប (ទិន្នផលស្រូវទាបតម្លៃស្រូវទាប ការចិញ្ចឹមសត្វក៏ថយចុះ តម្លៃសត្វនៅលើទីផ្សារមានតម្លៃទាប) និងប្រជាពលរដ្ឋប្រកបរបរនេសាទក៏ទៅមិនទទួលបានទិន្នផលខ្ពស់ធនធានជលផលថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

**ក.កសិកម្ម**

មនុស្សអាយុ ១៨ ឆ្នាំឡើងប្រកបរបរកសិកម្មជាចម្បងមានអត្រា ៥៦,៥០% ក្នុងនោះមានស្ត្រីអត្រា ២៤,៣០% នៃចំនួនមនុស្សប្រកបរបរកសិកម្ម។

វិស័យកសិកម្ម[២៤]បានផ្ដោតការយកចិត្តទុកដាក់លើការបង្កើនផលិតភាពដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនដូចជា៖ ការបង្កើនកិច្ចសហការផ្ដល់សេវាបច្ចេកទេសកសិកម្មដល់ពលរដ្ឋនិងការជួយអន្តរាគមន៍លើដំណាំកសិកម្មគ្រប់ប្រភេទក្នុងគោលដៅបង្កើនទិន្នផលការធ្វើបន្សាំការប្រែប្រួលអាកាសធាតុការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្មនិងការសហការជំរុញផលិតកម្ម និងសុខភាពសត្វ។

ប្រជាជនប្រមាណ ៣៩,៣០% មានមុខរបរធ្វើស្រែជាចម្បងនៃគ្រួសារប្រកបរបរកសិកម្មជាចំបងសរុបដូចនេះការងារបង្កបង្កើនផលស្រូវវស្សាអនុវត្តបានលើផ្ទៃដី ៩៦៩ហិតា ស្មើនឹង ៣៨,៩០% នៅផ្ទៃដីដែលបានធ្វើស្រែបានទិន្នផលមធ្យម ២តោន/ហ.ត បរិមាណផលសរុប ១៩៣៨តោន បរិមាណផលស្រូវប្រចាំឆ្នាំនេះប្រជាពលរដ្ឋទទួលបានចំនួនប៉ុន្មាន ២១៥គីឡូក្រាម សម្រាប់មនុស្សម្នាក់ម្នាក់ក្នុងមួយឆ្នាំផ្ទៃដីស្រែវស្សាទាំងអស់បានគ្រប់ដណ្ដប់ប្រព័ន្ធធារាសាស្ត្រការពារទឹកប្រៃ។

ប្រជាជនប្រមាណ ៧,៤០% មានរបបដាំដំណាំកសិឧស្សាហកម្មដំណាំរួមផ្សំនិងបន្លែអនុវត្តបានលើផ្ទៃដី ៤០ហិ.ត។

ប្រជាជនប្រមាណ ០,៧០% ការងារចិញ្ចឹមសត្វសម្រេចបាន គោសរុប ៦១៧ក្បាល ក្របីសរុប ៦៨៤ក្បាល ជ្រូកសរុប ៩៩៦ក្បាល។

ប្រជាជនប្រមាណ ៩% មានមុខរបរជាអ្នកនេសាទ[២៥]មានគ្រប់នេសាទតួម៉ាស៊ីនសម្រាប់នេសាទមានចំនួន ៩០ គ្រឿងមានទូកនេសាទទូកចែវទូកអុំមានចំនួន ៨៧គ្រឿងនឹងមានគ្រួសារបង្កើតវារីវប្បកម្មសមុទ្រត្រីទឹកសាប (គ្រួសារចិញ្ចឹមបង្គារមានអត្រា ០,១០% ) ។

ផ្អែកតាមសក្ដានុពល[២៦] និងសមិទ្ធផលក្នុងការអនុវត្តជាក់ស្ដែងកន្លងមកឃុំបាន និងកំពុងជួបប្រទះបញ្ហាប្រឈមគួរឲ្យកត់សម្គាល់ដូចជាផលបរិមាណផល និងគុណភាពស្រូវនៅមានកម្រិតមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទិន្នផលស្រូវដោយទិន្នផលស្រូវភូមិមួយចំនួនទទួលបានទិន្នផលសរុបជាមធ្យម ២តោន/ហ.ត ។

បញ្ហាប្រឈមទាំងនេះបណ្ដាលមកពីប្រព័ន្ធធារាសាស្ត្រការពារ និងរំដោះទឹកមិនគ្រប់គ្រាន់ខ្វះបច្ចេកទេសដាំដុះការប្រើប្រាស់ពូជសុទ្ធល្អ និងសត្វល្អិតបំផ្លាញ។ល។ ម្យ៉ាងទៀតដំណាំរួមផ្សំបន្លែបង្ការដំណាំ

[២៤]បញ្ហាប្រឈមក្នុងវិស័យកសិកម្ម ដកស្រង់ពីសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល

[២៥]មុខរបរអ្នកនេសាទ ប្រភពទិន្នន័យ CDB

[២៦]សក្ដានុពលនិងសមិទ្ធផល និងបញ្ហាប្រឈម ប្រភពទិន្នន័យ CDB

ឧស្សាហកម្មផ្សេងទៀត និងការចិញ្ចឹមសត្វក៏នៅមានកម្រិតទាបទាំងបរិមាណ និងគុណភាពមិនអាចបំពេញបានតាមតម្រូវការទីផ្សារដោយមូលហេតុចម្បងដូចជាកសិករខ្វះទុនបច្ចេកទេសប្រព័ន្ធស្រោចស្រពព័ត៌មានទីផ្សារនិងកម្លាំងពលកម្មបំរើការងារកសិកម្មថយចុះជាបន្តបន្ទាប់ក្នុងមួយឆ្នាំៗល។ ការប្រែប្រួលអាកាសធាតុបណ្ដាលឲ្យកើតមានគ្រោះមហន្តរាយធម្មជាតិខុសប្រក្រតីដូចជាជំនន់ទឹកភ្លៀង និងការចូលឡើងនៃកម្ពស់ទឹកសមុទ្រហូរចូលស្រែជាហេតុនាំឲ្យមានផលប៉ះពាល់ដល់ផលិតកម្មកសិកម្ម។

កំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើនប្រជាជនក៏បានស្រូបយកផ្ទៃដីកសិកម្មជារៀងរាល់ឆ្នាំដោយការសាងសង់លំនៅដ្ឋាននិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ កត្តាទាំងនេះហើយដែលបណ្តាលឱ្យផ្ទៃដីកសិកម្មក្នុងឃុំរួមតូចដូចនេះការអភិវឌ្ឍចាំបាច់ត្រូវមានវិធានការអភិវឌ្ឍតាមបែបស៊ីជម្រៅការប្រកបរបរកសិកម្មតាមបែបប្រពលវប្បកម្ម និងបង្កើនរដូវការកែលម្អដីធ្លីការប្រើប្រាស់ពូជជីសមស្របតាមគ្រឿងបរិស្ថាន ការអនុវត្តបច្ចេកទេសដាំដំណាំតាមដុះថ្មី ដែលជួសជុលប្រព័ន្ធធារាសាស្ត្របណ្តុះបណ្តាលបច្ចេកទេសជំនាញនិងកែប្រែទម្លាប់ដាំដុះរបស់កសិករ។

**ខ. អាជីវកម្ម សេវាកម្ម**

ការប្រកបរបរបលិទ្ធិកម្មសេវាកម្ម[២៧]ជាចម្បងមានអត្រា ៤៣,៥០% ក្នុងនោះស្ត្រីមានអត្រា ២៦,៣០% នៃចំនួនមនុស្សប្រកបរបរផលលិតកម្មសេវាកម្មសរុប។ ផ្នែកអាជីវកម្មបានយកចិត្តទុកដាក់ទៅលើការបង្កើតទីផ្សារដែលជាប្រភពសក្តានុពលសំខាន់សម្រាប់បង្កើតទីតាំងផលិតកម្ម សេវាកម្មនានា និងការផ្តល់នូវជំនាញបច្ចេកទេសផលិត និងជំនួញខ្នាតតូចបង្កើតមុខរបរសម្រាប់ការផ្គត់ផ្គង់ជីវភាពពលរដ្ឋនិងសហការជំរុញការផ្តល់ទុនប្រាក់កម្ចីរបស់មីក្រូហិរញ្ញវត្ថុ។

បច្ចុប្បន្នឃុំមានទីផ្សារមួយកន្លែងនៅភូមិអូរចំណារ ឃុំមានទីតាំងផលិតកម្មនិងសេវាកម្មចំនួន ៧៦ កន្លែង មាន រោងចក្រឧស្សាហកម្ម ម៉ាស៊ីនកិនស្រូវសេវាកម្មលក់ដូរចំណីអាហារជួសជុលម៉ូតូជួសជុលគ្រឿងយន្តនិងឧបករណ៍កសិកម្មជួសជុលគ្រឿងអេឡិចត្រូនិច និងសេវាកម្មទេសចរណ៍ប្រភពទឹកសក្តានុពលទេសចរណ៍ធម្មជាតិដែលអាចធ្វើការអភិវឌ្ឍជារមណីយដ្ឋានសម្រាប់បម្រើដល់វិស័យទេសចរណ៍ និងក៏អាចផ្តល់ចំណូលដល់ប្រជាពលរដ្ឋក្នុងឃុំបានដូចជាព្រៃកោងកាងនៅឧទ្យានជាតិរាម។ល។

រដ្ឋបាលឃុំបាន និងកំពុងពង្រឹងកិច្ចសហការជំរុញការផ្តល់សេវាផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ប្រជាពលរដ្ឋក្នុងឃុំមានអត្រា ៩០,២០% នៃចំនួនផ្ទះសរុបទូទាំងឃុំ។

ការប្រឈមនៃការកើតមានៈ ពលរដ្ឋភាគច្រើនមិនមានមុខរបរផ្នែកផលិតកម្មដោយខ្វះជំនាញវិជ្ជាជីវៈប្រភពទុនសម្រាប់បង្កើតនិងបង្កើនមុខរបរសក្តានុពលទេសចរណ៍ធម្មជាតិដែលអាចធ្វើការអភិវឌ្ឍជារមណីយដ្ឋានមិនទាន់មានលទ្ធភាពស្តារ និងអភិវឌ្ឍនៅឡើយនិងការផ្គត់ផ្គង់អគ្គិសនីមិនទាន់បានគ្រប់គ្រួសារនៅឡើយ។

**គ. គមនាគមន៍**

ស្ថានភាពប្រព័ន្ធគមនាគមន៍[២៨] បានផ្តល់ភាពងាយស្រួលដល់ការអភិវឌ្ឍគ្រប់ផ្នែកឃុំមានប្រព័ន្ធដឹកជញ្ជូនផ្លូវគោកមានបេតុងភ្ជាប់ពីផ្លូវជាតិលេខ ៤ និងផ្លូវក្នុងមូលដ្ឋានដោយបានក្រុមប្រឹក្សាបានធ្វើការស្តារ

[២៧]បញ្ហាប្រឈមក្នុងវិស័យអាជីវកម្ម សេវាកម្ម ដកស្រង់ពីសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល

[២៨]បញ្ហាប្រឈមក្នុងវិស័យគមនាគមន៍ ដកស្រង់ពីសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល

និងជួសជុលឡើងតាមរយៈការប្រើប្រាស់មូលនិធិឃុំរួមមានផ្លូវក្រៅគ្រួសក្រហម ផ្លូវក្រាលបេតុង និងប្រព័ន្ធដឹកជញ្ជូនផ្លូវទឹកមាន សេវាដឹកអ្នកទេសចរប្រព័ន្ធផ្លូវទាំងពីរប្រភេទ គឺជាប្រភពសក្តានុពលសំខាន់ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយ ក្រុង ស្រុក ខេត្តនិងការធ្វើចរាចរណ៍ នូវកសិផលនិងធនធានជលផលមួយចំនួននៅទីផ្សារក្រុង ស្រុក ជាប់សមុទ្រ។ ទន្ទឹមនិងភាពរីកចម្រើនផ្នែកសក្តានុពលដឹកជញ្ជូន ឃុំក៏ជួបប្រទះនូវបញ្ហាសំខាន់ៗដូចជាប្រព័ន្ធផ្លូវមួយចំនួនត្រូវរងការខូចខាត និងមួយចំនួនទៀតមានសភាពចាស់ទ្រុឌទ្រោម ត្រូវទឹកហូរកាត់ខូចដោយគ្មានការប្រព័ន្ធលូរំដោះទឹក និងមិនមានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការស្តារថែទាំ និងជួសជុលឡើងវិញដែលអាចបំពេញតាមតម្រូវការរបស់មូលដ្ឋាន។

**ឃ. ការវិនិយោគ**

វិស័យឯកជនបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ស្ថានភាពនៃការវិនិយោគរបស់អ្នកវិនិយោគិន[២៩]ក្នុងស្រុកបាននិងកំពុងផ្តោតលើវិស័យមួយចំនួនដូចជា កសិកម្ម (វារីវប្បកម្មបង្គានិងចិញ្ចឹមត្រីទឹកសាបជាលក្ខណៈគ្រួសារ) និងការអភិវឌ្ឍតំបន់ទេសចរណ៍មានសេវាកម្មស្នាក់នៅផ្ទះសំណាក់ចំនួន ៤ កន្លែង និងកន្លែងកំសាន្ត ការអភិវឌ្ឍលើវិស័យឧស្សាហកម្ម ( រោងចក្រ និងសហគ្រាស) ដែលបានផ្តល់លទ្ធភាពដល់ប្រជាជនក្នុងឃុំចូលរួមបម្រើការងារប្រមាណ ១៩៤២ នាក់ ក្នុងនោះស្ត្រីមាន ១២១៤នាក់។

ការជួបប្រទះចំពោះការវិនិយោគនៃការអភិវឌ្ឍន៍ពុំមានការចូលរួមពីអាជ្ញាធរក្នុងមូលដ្ឋាន និងការវិនិយោគមិនបានបម្រើដល់ការងារធ្វើអាជីវកម្មរបស់ប្រជាពលរដ្ឋគឺការវិនិយោគមានលក្ខណៈខ្នាតតូច។

**២.១.២.២ ស្ថានភាពសង្គមកិច្ច**

**ក. ការអប់រំ**

ការងារអប់រំក៏ទទួលបាននូវការគាំទ្រពីរាជរដ្ឋាភិបាលនិងបានធ្វើការអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធអប់រំចាប់ពីថ្នាក់មត្តេយ្យរហូតដល់សាលាអនុវិទ្យាល័យ ធ្វើឲ្យវិស័យអប់រំមានលទ្ធភាពផ្តល់ការអប់រំកម្រិតមូលដ្ឋានដល់កុមារស្ថិតក្នុងវ័យសិក្សាទាំងអស់ជាពិសេសកុមារដែលជាកូនមកពីគ្រួសារក្រីក្រទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងមានលទ្ធភាពបញ្ចប់ការសិក្សាអប់រំកម្រិតមូលដ្ឋានត្រឹមថ្នាក់ទី៩តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ស្ថានភាពអប់រំ[៣០]បច្ចុប្បន្នមាន៖

ភូមិមានសាលាមត្តេយ្យរដ្ឋមានចំនួន ២សាលា មាន ៣ថ្នាក់ មត្តេយ្យសហគមន៍មានចំនួន ៣ថ្នាក់ កុមារក្រុមអាយុ ៣-៤ ឆ្នាំ បានចូលរៀនមានចំនួន ២៨៥នាក់ អត្រាប្រមាណ ៣៩,៥០% និងកុមារក្រោមអាយុ ៦ ឆ្នាំស្មើនឹងអត្រា ១១,៤០% នៃចំនួនកុមារក្រោមអាយុ ១២-១៤ ឆ្នាំបានចូលរៀនសរុប។

សាលាអនុវិទ្យាល័យមានមួយសាលា នាងដប់បន្ទប់មានថ្នាក់ចំនួនប្រាំមួយថ្នាក់កុមារអាយុ ១២-១៤ ឆ្នាំកំពុងនៅរៀនមានចំនួន ៣៣៦ នាក់ស្មើនឹង ៤៩,៩០% នៃចំនួនកុមារក្រុមអាយុ ១២-១៤ឆ្នាំបានចូលរៀនសរុប។ កុមារអាយុ ១៥-១៧ឆ្នាំ កំពុងរៀនមានចំនួន ៤៣៧នាក់ ស្មើនឹង ៥១,១៣% នៃចំនួនកុមារក្រុមអាយុ ១៥-១៧ឆ្នាំ។

---

[២៩]បញ្ហាប្រឈមក្នុងការវិនិយោគ ដកស្រង់ពីសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល

[៣០]ស្ថានភាពអប់រំ ប្រភពទិន្នន័យព័ត៌មានមូលដ្ឋានភូមិឃុំដើមឆ្នាំ ២០១៨

ការផ្តល់សេវាអប់រំតាមមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋគ្រប់រូបនៅពុំទាន់មានភាពល្អប្រសើរនៅឡើយ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធអប់រំមានស្ទើរតែគ្រប់គ្រាន់ក៏ដោយ តែនៅមិនទាន់មានថ្នាក់មត្តេយ្យគ្រប់គ្រាន់នៅតាមតម្រូវការ និងកំណើតរបស់កុមារក្នុងមូលដ្ឋាននៅឡើយ។

ចំណែកកុមារក្រុមអាយុ ១២-១៤ឆ្នាំមិនបានចូលរៀនមានអត្រាខ្ពស់នៅឡើយ និងក្រុមកុមារ ១៥-១៧ ឆ្នាំរៀននៅសាលាអនុវិទ្យាល័យនិងវិទ្យាល័យមានកម្រិតទាបពិសេសកុមាររស់នៅភូមិអូរតាសេក និងប្រជាពលរដ្ឋដែលរស់នៅជិតទីតាំងចាក់សំរាមដោយសាលានៅឆ្ងាយ និងភាគច្រើនចេញទៅប្រកបរបររកប្រាក់ចំណូលសម្រាប់គ្រួសារ។

**ខ. សុខាភិបាល**

សុខភាពប្រជាពលរដ្ឋទទួលបាននូវការផ្តល់សេវាថែទាំព្យាបាលមិនទាន់ពេលវេលាដោយមជ្ឈមណ្ឌលសុខភាពឃុំមានភាពល្អប្រសើរទាំងការផ្គត់ផ្គង់ និងការផ្តល់សេវាថែទាំព្យាបាលសាធារណៈដូចជាការជួយគាំពារនិងថែរក្សាការពារសុខភាពផ្តល់នូវអាហារូបត្ថម្ភ និងការចាក់វ៉ាក់សាំងការពារដល់ស្ត្រី កុមារការផ្សព្វផ្សាយបង្កើនការយល់ដឹងពីការថែទាំសុខភាពអនាម័យ និងជំងឺឆ្លងនានា ការអប់រំបង្កើនការយល់ដឹងដល់យុវជនពីសុខភាពបន្តពូជតាមរយៈការបង្កើតបណ្តាញភ្នាក់ងារសុខភាពភូមិ។

ឃុំមានសេវាសុខភាព[៣១]ដូចជា៖

- មណ្ឌលសុខភាពមាន០១កន្លែង
- ទីតាំងកន្លែងព្យាបាលឯកជនមាន០៣កន្លែង
- ឱសថស្ថានរងចំនួន ០៥ កន្លែង

ទោះជាយ៉ាងណាគាត់នៅមានបញ្ហាមួយចំនួនដែលវិស័យសុខាភិបាលត្រូវផ្តល់ការយកចិត្តទុកដាក់ដូចជាអត្រាមរណភាពរបស់មាតាក្រោយពេលសម្រាលនៅតែមានដោយការខ្វះការយល់ដឹងពីការត្រៀមជុំវិញកំណើតនិងសេវាដឹកជញ្ជូនមិនទាន់បានល្អប្រសើរទារក និងកុមារតូចនាយឆ្លងជំងឺដោយសារខ្វះការចូលរួមថែទាំពីនេះម្តាយឪពុកការផ្តល់សេវាព្យាបាលនៅមានកម្រិត។

សេវាផ្សព្វផ្សាយពីសុខភាពបន្តពូជនិងប្រជាពលរដ្ឋនៅមានជំងឺឆ្លងព្រោះមិនយល់ដឹងពីការថែទាំសុខភាពនិងវិធានការការពារ។

**គ. យេនឌ័រ**

ភាពរស់នៅរបស់ពលរដ្ឋតាមសហគមន៍ប្រកបដោយភាពស្មើភាពគ្នា និងគ្មានអំពើហិង្សាដោយកន្លងមកក្រុមប្រឹក្សាឃុំ និងជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារក៏បានខិតខំសហការជាមួយបណ្តាលស្ថាប័នជំនាញ និងបណ្តាអង្គការនានាជុំវិញការបញ្ជ្រាបគោលគំនិតយេនឌ័រ[៣២]ដល់សហគមន៍មូលដ្ឋានទូទាំងឃុំតាមរយៈការអប់រំដោយផ្សព្វផ្សាយពីច្បាប់នានាដែលពាក់ព័ន្ធដោយបានបង្ហាញពីជីវភាពរស់នៅប្រកបដោយសមភាព

---

[៣១]សេវាសុខភាព ប្រភពអង្កេតតាមស្ថានភាពបច្ចុប្បន្នឆ្នាំ២០២០

[៣២]យេនឌ័រ ដកស្រង់ពីសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល

និងសមធម៌រវាងបុរសស្ត្រីពីសិទ្ធិបញ្ចេញមតិរបស់ស្ត្រី និងតួនាទីស្ត្រីចូលរួមក្នុងការអភិវឌ្ឍសង្គមការយល់ដឹងនូវបញ្ហាជាមូលដ្ឋានសម្រាប់កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។ ទន្ទឹមនឹងនោះក៏បានជំរុញឲ្យស្ត្រីទទួលយកនូវចំណេះដឹងជំនាញវិជ្ជាជីវៈលើកកម្ពស់សមត្ថភាពស្ត្រីឈានទៅយកភាពសមធម៌ការងារក្នុងសង្គម។

- ស្ត្រីប្រកបមុខរបរធ្វើកសិកម្មជាចម្បងមានអត្រា ២៤,៣០%
- មនុស្សស្រីមានមុខរបរចម្បងក្រៅពីវិស័យកសិកម្មជាចម្បងមានអត្រា ៦០,៦០%
- ស្ត្រីធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្នុងប្រទេសមានចំនួន ២,៨០% នៃចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេសនិងស្ត្រីធ្វើចំណាកស្រុកនៅក្រៅប្រទេសមានអត្រា ០,៨០% នៃចំនួនមនុស្សធ្វើចំណាកស្រុកក្រៅប្រទេស។
- ផលធៀបត្រីក្នុងបុរស ១០០ នាក់ដែលនៅរៀនសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ ( អាយុ ១៨-៣៥ឆ្នាំ) មាន៨៣,៣នាក់
- ស្ត្រីចេះអក្សរអាយុ ១៨-៤៥ឆ្នាំ មានអត្រា ៦០,៩០%
- ស្ត្រីជាគ្រូបង្រៀនសាលាអនុវិទ្យាល័យមានអត្រា ២៨,៩០%
- ស្ត្រីជាជនពិការមានអត្រា ៤០,៤០%
- ការសម្រេចចិត្តចូលរួមក្នុងចលនាអភិវឌ្ឍសង្គមដូចជាក្រុមប្រឹក្សាឃុំនៅមានកម្រិតទាប។

បញ្ហាមួយចំនួនដែលមាននៅក្នុងផ្នែកយេនឌ័រសម្រាប់ដោះស្រាយបន្តភាគរយស្ត្រីជាមួយគ្រួសារមានអត្រា ១៨,៨០%។

**ឃ. សាសនា**

ពលរដ្ឋក្នុងឃុំមាន៤ជនជាតិ[៣៣]គឺជាជនជាតិខ្មែរមានអត្រាប្រមាណ ៧០% និងជនជាតិខ្មែរអ៊ីស្លាមមានអត្រាប្រមាណ ២៨,៥% ជនជាតិចិន ១,៤០% ជនជាតិវៀតណាម ០,១០% ក្នុងនោះមានៈ

- ជនជាតិខ្មែរកាន់សាសនាព្រះពុទ្ធមានវត្តចំនួន ២
- ជនជាតិខ្មែរឥស្លាមកាន់សាសនាឥស្លាមមានព្រះវិហារចំនួន ៣
- ជាតិខ្មែរកាន់សាសនាយេស៊ូមានអត្រាប្រមាណសូន្យចុច ០,២០% មានព្រះវិហារចំនួន ១ កន្លែង

**ខ. អន្តោប្រវេសន៍ និងការផ្លាស់លំនៅ**

បច្ចុប្បន្នប្រជាពលរដ្ឋដែលបានផ្លាស់ប្ដូរទីលំនៅមករស់នៅក្នុងឃុំអូរឧកញ៉ាហេងភាគច្រើនគឺប្រកបរបរនេសាទ និងប្រកបអាជីវកម្មទេសចរណ៍ដោយមានប្រភពសក្ដានុពលលើប្រភពធនធានជលផលដោយឃុំមានតំបន់វារីវប្បកម្មមានតំបន់ព្រៃកោងកាង មានធនធានជលផលចំរុះដូចជា បង្គា ត្រី ផ្នែកទេសចរណ៍ឃុំមាន តំបន់ឧទ្យាន អ្នកតំបន់សមុទ្រ និងជាកម្មករធាងចក្រតាមសហគ្រាសនានា។

[៣៣]ជំរឿនស្ថិតិឃុំឆ្នាំ២០១៨

## ២.២ ការរៀបចំផែនការអភិវឌ្ឍន៍របស់ឃុំអូរឧកញ៉ាហេង

### ២.២.១ ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍

ប្រជាពលរដ្ឋមានកំរិតជីវភាពល្អប្រសើរ *មានសមត្ថភាព* [៣៤] គ្រប់គ្រាន់រស់នៅប្រកបដោយផាសុខភាព និងបរិស្ថានស្អាតមានអនាម័យមានសន្តិសុខស ណ្តា ប់ ធ្នា ប់ ល្អ នឹ ង ទ ទួ ល បា ន សេវាសាធារណៈប្រកបដោយសមធម៌។

គោលបំណងអភិវឌ្ឍន៍៖

- ពលរដ្ឋទទួលបានប្រាក់ចំណូលខ្ពស់ពីវិស័យកសិកម្មមានជីវភាពល្អប្រសើរ។
- ការធ្វើដំណើររបស់ប្រជាពលរដ្ឋនិងអ្នកទេសចរទាំងផ្លូវទឹកនិងផ្លូវគោកមានភាពងាយស្រួល និងប្រកបដោយសុវត្ថិភាព។
- ប្រជាពលរដ្ឋគ្រប់រូបមានសមត្ថភាពជំនាញចំណេះដឹងក្នុងការប្រកបរបរសេវាកម្មផលិតកម្ម នឹងទទួលបាននូវប្រាក់ចំណូលខ្ពស់ការធ្វើចំណាកស្រុកបានកាត់បន្ថយជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។
- ពលរដ្ឋមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ក្រុមគ្រួសារ។
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពលើការអប់រំនៅគ្រប់មូលដ្ឋានសិក្សាបង្កើនការអប់រំកុមារបានចូលរៀនគ្រប់គ្នានិងអក្ខរភាពត្រូវបានលុបបំបាត់។
- ពលរដ្ឋមានសុខភាពមាំមួនទទួលបាននូវសេវាសុខាភិបាលសាធារណៈគ្រប់គ្រាន់កាត់បន្ថយការឈឺស្លាប់របស់មាតាទារកកុមារ កាត់បន្ថយអត្រាស្លាប់ និងឆ្លងជំងឺដោយសារជំងឺអេដស៍ នឹងជំងឺរបេងគ្រុនចាញ់ និងជំងឺផ្សេងៗទៀត។
- ក្រុមជនងាយរងគ្រោះ និងក្រុមជនរងគ្រោះទទួលសេវាថែទាំឧបត្ថម្ភគាំពារសុខភាព និងមានសុវត្ថិភាពល្អប្រសើរជនពិការ និងកុមារកំព្រាមានលទ្ធភាព និងសមត្ថភាពចេញទៅប្រកបរបរតាមទីផ្សារ។
- ស្ត្រីមានសមត្ថភាពមានវិជ្ជាជីវៈគ្រប់គ្រាន់ និងមានលទ្ធភាពចូលបម្រើការងារក្នុងសង្គមប្រកបដោយសមធម៌ពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់ក្រុមគ្រួសារ និងរស់នៅក្នុងបរិស្ថានស្អាតគ្មានការបំពុលបរិស្ថានទាំងនៅលើគោកនិងទឹកសមុទ្រ។
- ពលរដ្ឋមិនរងគ្រោះដោយសារជំនន់ទឹកភ្លៀងជន់លិចទេគឺមានប្រព័ន្ធផ្លូវបង្ហូរទឹក និងរំដោះទឹកចេញពីទីប្រជុំជន(ទីផ្សារ) និងភូមិការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីក្នុងដែនរដ្ឋបាលឃុំស្រទៅតាមច្បាប់កំណត់គ្រោះដោយសារអំពើជួញដូរ និងអំពើហិង្សា។
- ពលរដ្ឋបានយល់ដឹងពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាននិងមកចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ៗគ្នា។

---

[៣៤]ចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍ "ប្រជាជនមានកម្រិតជីវភាពល្អប្រសើរ សមត្ថភាព គ្រប់គ្រាន់" ដកស្រង់ពីសៀវភៅផែនការអភិវឌ្ឍឃុំអូរឧកញ៉ាហេង ២០១៨

- ពលរដ្ឋរស់នៅប្រកបដោយសុខដុមរមនាមានសន្តិសុខសណ្តាប់ធ្នាប់ល្អប្រសើររដ្ឋបាលឃុំ និងភូមិមានទីកន្លែងល្អប្រសើរសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ
- ពលរដ្ឋបានយល់ដឹងនិងចេះគោរពច្បាប់ចរាចរណ៍។

### ២.២.២ គោលដៅអភិវឌ្ឍផ្នែកសេដ្ឋកិច្ច

- ផ្តល់ទិន្នផល និងផលិតផលកសិកម្មកើនឡើងប្រកបដោយគុណភាពល្អអាចធ្វើចរាចរណ៍នៅទីផ្សារតាមតម្រូវការ
- ពលរដ្ឋមានសមត្ថភាពជំនាញចំណេះដឹង និងមានទិដ្ឋភាពអាចប្រកបរបរកសិកម្ម
- ស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងកិច្ចការពារសុវត្ថិភាពការធ្វើចរាចរណ៍
- កាត់បន្ថយការធ្វើចំណាកស្រុក
- ពលរដ្ឋប្រកបរបរសេវាកម្ម និងប្រតិកម្មការឡើង
- ស្ត្រីមានចំណេះដឹងចូលរួមប្រកបរបរក្រៅពីកសិកម្ម និងមានលទ្ធភាពរកប្រាក់ចំណូលតាមទីផ្សារពលកម្មក្នុងមូលដ្ឋាន
- ពលរដ្ឋមានលទ្ធភាព និងសម្រាប់ភាពអាចទទួលចំណូលពីវិស័យទេសចរណ៍
- ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ។

### ២.២.៣ គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច

- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅគ្រប់ភូមិសិក្សា (មតេយ្យ បឋមសិក្សានិងអនុវិទ្យាល័យ) អរគុណឲ្យកុមារបានចូលរៀនគ្រប់ៗគ្នា។
- លុបបំបាត់អក្ខភាព។
- កាត់បន្ថយការឈឺ និងស្លាប់របស់មាតាទារកកុមារអត្រាស្លាប់ និងឆ្លងជំងឺអេដស៍ អ្នកស្លាប់និងឆ្លងដោយសារជំងឺរបេងគ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗទៀត។
- ក្រុមជនងាយរងគ្រោះ និងក្រុមជនងាយរងគ្រោះទទួលសេវាថែទាំឧបត្ថម្ភមណ្ឌលសុខភាព និងសុវត្ថិភាពល្អប្រសើរជនពិការ និងកុមារភាពកំព្រាមានលទ្ធភាព និងសមត្ថភាពចេញទៅប្រកបរបរតាមទីផ្សារលើកកម្ពស់ស្ត្រីបានចូលបម្រើការងារក្នុងសង្គម។

### ២.២.៤ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថានការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ

- ពលរដ្ឋរស់នៅក្នុងបរិស្ថានស្អាតមានបង្គន់អនាម័យអត្រា ៨០%
- ទឹកស្អាតប្រើប្រាស់គ្រប់ក្រុមគ្រួសារអត្រា ៨០%
- ស្តារ និងអភិវឌ្ឍប្រព័ន្ធលូ និងរំដោះជំនន់ទឹកភ្លៀងមិនអោយមានការលិចលង់តាមទីផ្សារ និងភូមិ
- ពលរដ្ឋបានយល់ដឹងពីការគ្រប់គ្រង និងទុកដាក់កាកសំណល់រឹងរាវមិនឲ្យប៉ះពាល់ដល់បរិស្ថាន និងមិនមានការបំពុលទឹកសមុទ្រ

- ពង្រឹងកិច្ចការពារធនធានព្រៃឈើព្រៃលិចទឹក (ព្រៃកោងកាង) ឱ្យមាននិរន្តរភាពការពារធនធានជលផលមាននិរន្តរភាព និងបង្កើនវារីវប្បកម្ម។

### ២.២.៥ គោលដៅអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- កាត់បន្ថយទំនាស់ដីធ្លី
- កាត់បន្ថយភាពងាយរងគ្រោះស្ត្រីកុមារដោយសារការជួញដូរ និងការរំលោភផ្លូវភេទ
- កាត់បន្ថយភាពងាយរងគ្រោះស្ត្រីកុមារដោយសារអំពើហិង្សា
- ពលរដ្ឋបានទៅទទួលការយល់ដឹងពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន[៣៥]
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- សន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានភាពល្អប្រសើរឡើង
- រដ្ឋបាលឃុំ និងភូមិមានទីកន្លែងល្អប្រសើរសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ។

## ២.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍

### ២.៣.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

- ជម្រុញការស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។
- បង្កើនការផ្តល់ចំណេះដឹងផ្នែកបច្ចេកទេសដំណាំស្រូវបង្កើនទិន្នផលស្រូវ។
- ជួយការផ្តល់ និងផ្សព្វផ្សាយពូជស្រូវដែលមានទិន្នផលខ្ពស់ និងសេវាផ្សព្វផ្សាយកសិកម្ម។
- ពង្រឹងការផ្សព្វផ្សាយ និងលើកទឹកចិត្តដល់ប្រជាកសិករ និងការធ្វើស្រែតាមបែបប្រពលវប្បកម្ម
- ពង្រឹងសមត្ថភាព និងការគ្រប់គ្រងសហគមន៍កសិកម្ម។
- ជំរុញការផ្តល់បច្ចេកទេសដាំដំណាំ និងពង្រឹងភ្នាក់ងារកសិកម្មជួយអន្តរាគមន៍ទាន់ពេលវេលា និងការប្រើពូជដំណាំបង្កើនគុណភាព។
- បង្កើនការផ្តល់បច្ចេកទេសយល់ដឹងពីសុខភាពសត្វ និងជំងឺឆ្លង។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធទប់ស្កាត់ការនាំចូល និងការជួយរកទីផ្សារប្រទេសផលសត្វជូនកសិករ។
- ជំរុញការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។
- ជំរុញការអភិវឌ្ឍន៍ប្រព័ន្ធរំដោះ និងបង្ហូរទឹកការពារគុណភាពផ្លូវ។
- សហការបង្កើនការផ្សព្វផ្សាយព័ត៌មានឧតុនិយម។
- ជំរុញការផ្តល់ជំនាញវិជ្ជាជីវៈជំនាញអាជីវកម្មកសិកម្ម និងការសហការផ្តល់ទុនបង្កើតមុខរបរ។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអង្គការពាក់ព័ន្ធជួយ ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពស្ត្រីបង្កើនភាពអង់អាចចូលរួមអភិវឌ្ឍផ្នែកសេដ្ឋកិច្ចដើម្បីឱ្យមានជម្ងឺចិត្តលើខ្លួនឯងពីការធ្វើអាជីវកម្មឬការរកប្រាក់ចំណូលផ្សេងៗ។

[៣៥]ការចុះបញ្ជីអត្រានុកូលដ្ឋាន មាននៅអនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០។ អនុក្រឹត្យលេខ ៦០ និង លេខ ១៧, ចុះនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០២ និង ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៤, ស្តីពីការកែសម្រួលនៃអនុក្រឹត្យលេខ ១០៣

- បង្កើនការយល់ដឹងពីផលប៉ះពាល់នៃការធ្វើចំណាកស្រុក និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។
- សហការជំរុញការផ្តល់ជំនាញវិជ្ជាជីវៈផ្នែកទេសចរណ៍។
- បង្កើតធនធានមនុស្សដើម្បីកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទេសចរណ៍ និងធ្វើការស្តារអភិវឌ្ឍន៍នៅរមណីយដ្ឋានលែងមានស្រាប់ រមណីយដ្ឋានដែលរងការបំពុលបរិស្ថានឲ្យមានសោភ័ណភាពសម្រាប់ភ្ញៀវទេសចរ។
- ពង្រឹងវិធានការការពាររមណីយដ្ឋានធម្មជាតិ។
- បង្កើនកិច្ចសហការជំរុញការរៀបចំបណ្តាញអគ្គិសនីឲ្យបានដល់ផ្ទះប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.៣.២ យុទ្ធសាស្រ្តអភិវឌ្ឍន៍សង្គមកិច្ច

- ជម្រុញការអប់រំផ្សព្វផ្សាយដល់ឪពុកម្តាយឲ្យយល់ដឹងពីតម្លៃនៃការសិក្សារបស់កុមារតូចៗ បង្កើនកិច្ចការសហការជាមួយដៃគូអភិវឌ្ឍន៍ពង្រីកការគាំទ្រតាមគ្រប់រូបភាពហ្នឹងឲ្យសាលាមត្តេយ្យរដ្ឋ និងដីសហគមន៍មានដំណើរការល្អប្រសើរឡើង។
- បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងមន្ទីរអប់រំជួយបង្កើនសាលាមត្តេយ្យ និងមត្តេយ្យសិក្សាសហគមន៍បានគ្រប់តាមតម្រូវការ។
- ពង្រឹងកិច្ចសហការជំរុញការជួយគាំទ្រដល់មធ្យោបាយធ្វើដំណើរនានាដល់គ្រួសារសិស្សក្រីក្រ និងការផ្តល់អាហារូបករណ៍បង្កើនការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីតម្លៃនៃការសិក្សាដល់មូលដ្ឋានដាច់ស្រយាល។
- ពង្រីកការផ្សព្វផ្សាយ និងបង្កើនការប្រមូលកុមារដល់អាយុចូលរៀន (៦-១៤ឆ្នាំ) នៅបឋមសិក្សា និងអនុវិទ្យាល័យនិងការផ្សព្វផ្សាយ និងជំរុញឲ្យពលរដ្ឋមានការចូលរួមលើកកម្ពស់អក្ខរកម្ម និងលុបបំបាត់អក្ខរសុភាព។
- សហការនិងជំរុញបង្កើតឥណទានកម្ចីការប្រាក់ទាប ដើម្បីផ្តល់ដល់សិក្ខាកាមប្រជាពលរដ្ឋដែលបានឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈរួច និងគ្មានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួនប្រចាំគ្រួសារ។
- បង្កើនការយល់ដឹងអំពីការថែរក្សាសុខភាពដល់ស្រ្តីដែលមានផ្ទៃពោះ និងស្រ្តីក្រោយសម្រាល និងជំរុញការផ្តល់សេវាពិនិត្យផ្ទៃពោះនៅតាមមូលដ្ឋាន បង្កើនការយល់ដឹងពីការសម្រាលកូន និងគាំទ្រមធ្យោបាយធ្វើដំណើរដល់ស្រ្តីមានបញ្ហាពេលសម្រាល។
- បង្កើនការទទួលយកសេវាសុខភាពសម្រាប់កុមារថែទាំសុខភាពពលរដ្ឋតាមគ្រួសារឱ្យបានដល់ប្រសើរ និងបង្កើនការយល់ដឹង និងសហការជំរុញការផ្តល់ពីអាហារូបត្ថម្ភដល់ស្រ្តី ទារក និងកុមារអាយុក្រោម ៥ ឆ្នាំ
- ពង្រឹង និងពង្រីកការផ្តល់សេវាសុខភាពបន្តពូជសកម្មភាពពន្យារកំណើត និងការចាក់ថ្នាំការពារដល់ស្រ្តីក្នុងវ័យបន្តពូជ

- សហការផ្សព្វផ្សាយ និងជំរុញដល់ប្រជាពលរដ្ឋដែលកើតជំងឺអេដស៍មកទទួលយកសេវាថែទាំសុខភាព និងបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយអំពីជំងឺអេដស៍ និងជំងឺកាមរោគជំរុញការផ្តល់សេវាថែទាំគាំពារជំងឺអេដស៍
- ពង្រឹង និងពង្រីកសេវាការពារ និងបង្ការការចម្លងពីម្តាយទៅកូនផ្តល់ការយល់ដឹងជំរុញការថែទាំសុខភាពគាំពារសុខភាព និងមានវិធានការទប់ស្កាត់នៃការឆ្លងជំងឺគ្រប់ប្រភេទ
- បង្កើនកិច្ចការការជំរុញការផ្តល់សេវាសង្គម ជួយថែទាំឧបត្ថម្ភគាំពារសុខភាព និងសុវត្ថិភាព និងបង្កើនកិច្ចសហការបង្កើតសហគមន៍ជនរងគ្រោះ
- ផ្សព្វផ្សាយ និងជំរុញក្រុមជនងាយរង និងក្រុមងាយរងគ្រោះមកទទួលយកសេវាថែទាំបឋមគាំពារសុខភាព និងសុវត្ថិភាពបង្កើនការផ្តល់ចំណេះដឹង និងសមត្ថភាពជំនាញវិជ្ជាជីវៈសមស្រប នឹងការផ្សព្វផ្សាយលុបបំបាត់ភាពរើសអើង
- សហការជាមួយស្ថាប័នពាក់ព័ន្ធជួយជំរុញ និងឱ្យគ្រប់ស្ថាប័នរដ្ឋ និងឯកជនអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល
- អនុសាសន៍ ឬព័ត៌មានត្រឡប់ផ្តល់ការលើកទឹកចិត្តជួយដោះស្រាយរាល់បញ្ហាដែលជួបប្រទះគាំទ្រជួយផ្តល់ឱកាសឱ្យស្ត្រីចូលរួមក្នុងកម្មវិធីផ្សេងៗដូចជា សិក្ខាសាលា និងជំរុញការផ្តល់ចំនេះដឹងស្តីអំពីការបញ្ជ្រាបយេនឌ័របរិយាបន្ន[៣៦] និងសមធម៌សង្គម។

**២.៣.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំ និងអាកាសធាតុ**

- សហការជំរុញឱ្យមានបណ្តាញការផ្គត់ផ្គង់អណ្តូងទឹកស្អាតនិងបង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាត
- សហការបង្កើនការផ្គត់ផ្គង់បង្គន់អនាម័យ និងផ្តល់សម្ភារៈសាងសង់បង្គន់ និងបង្កើនការផ្សព្វផ្សាយពីការប្រើប្រាស់បង្គន់អនាម័យនិងការថែរក្សាអនាម័យបរិស្ថាន
- បង្កើនការយល់ដឹងពីការគ្រប់គ្រងទុកដាក់កាកសំណល់ និងការផ្តល់សម្ភារៈទុកដាក់កាកសំណល់តាមទីសាធារណៈ និងទីប្រជុំជន
- ជំរុញឲ្យសេវាប្រមូល និងដឹកជញ្ជូនកាកសំណល់បានទាន់ពេលវេលា និងឱ្យមានប្រជាពលរដ្ឋទទួលយកសេវាប្រមូលកាកសំណល់
- ជម្រុញការស្តារ និងរៀបចំប្រព័ន្ធទុកដាក់និងបង្ហូរទឹកស្អុយការស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធរំដោះទឹក
- បង្កើនយល់ដឹងការគ្រប់គ្រងទុកដាក់កាកសំណល់រាវមិនឲ្យហូរចូលក្នុងសមុទ្រ និងជំរុញឲ្យបង្កើតប្រព័ន្ធការពារ និងទុកដាក់កាកសំណល់រាវ
ពង្រឹងវិធានការទប់ស្កាត់ការបង្ហូរកាកសំណល់ និងការចាក់ដីចូលសមុទ្រ និងការបំពានយកដីចំណីផ្លូវ និងប្រឡាយអូរជាកម្មសិទ្ធិ

[៣៦]យេនឌ័របរិយាបន្ន ស្ថិតក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ នៃគោលដៅគោលដៅទី៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

- ពង្រឹងវិធានការគ្រប់គ្រងការការពារទប់ស្កាត់ការបំផ្លាញព្រៃឈើយកដីជាកម្មសិទ្ធិ និងការធ្វើអាជីវកម្មលើព្រៃឈើហួសកម្រិត
- បង្កើនការយល់ដឹងពីច្បាប់ និងសារៈប្រយោជន៍ព្រៃឈើ និងពង្រឹងវិធានការគ្រប់គ្រងការការពារទប់ស្កាត់ការប្រម៉ាញ់សត្វ
- បង្កើតសហគមន៍នេសាទការពារព្រៃលិចទឹក និងតំបន់អភិរក្សជម្រកត្រីជំរុញការផ្សព្វផ្សាយច្បាប់ និងពង្រឹងវិធានការទប់ស្កាត់បទល្មើសនេសាទ
- ពង្រឹងវិធានការទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក និងការធ្វើអាជីវកម្មក្នុងតំបន់អភិរក្ស និងបង្កើតជម្រកត្រីសប្បនិមិត្ត
- សារការជម្រុញផ្តល់ជំនាញវារីវប្បកម្ម និងផ្តល់ពូជនិងទប់បង្កើតមុខរបរ។

**២.៣.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

- បង្កើតផ្សព្វផ្សាយច្បាប់ភូមិបាល ក្នុងការធ្វើជាកម្មសិទ្ធករនៃដី[៣៧] និងច្បាប់នានាពង្រឹងការអនុវត្តច្បាប់ភូមិបាល និងជំរុញការចុះវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី
- បង្កើនការយល់ដឹងពីច្បាប់ប្រើប្រាស់ពលកម្មកុមារការជួញដូរមនុស្ស និងពង្រឹងវិធានការទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់ពលកម្មកុមារ[៣៨]
- បង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា ពង្រឹងវិធានការអប់រំទប់ស្កាត់នូវគ្រប់គ្រង និងបង្កើនសកម្មភាពជួយសង្គ្រោះជនរងគ្រោះ បន្តពង្រឹងការជួយឧបត្ថម្ភដល់គ្រួសារក្រីក្រ បន្តកិច្ចសហការជួយថែរក្សាគម្ពីរសុខភាព និងសុខមាលភាពរបស់ពួកគាត់ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលសហការផ្តល់ជំនាញចំណេះដឹង និងការជួយផ្តល់ទុនសម្រាប់បង្កើតមុខរបរ
- បង្កើនការផ្តល់ចំណេះដឹងស្តីអំពីការលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រីនិងគ្រួសារខ្មែរ
- បង្កើនការយល់ដឹងពីសារប្រយោជន៍នៃអត្រានុកូលដ្ឋានជំរុញការផ្តល់សេវា និងការបង្កើនការផ្សព្វផ្សាយពលរដ្ឋដែលមានកាយទទួលយកនូវសេវាអត្រានុកូលដ្ឋាន
- បង្កើនការយល់ដឹងពីច្បាប់ពង្រឹងវិធានការអនុវត្តច្បាប់ចរាចរណ៍
- បង្កើនការផ្សព្វផ្សាយ និងពង្រឹងវិធានការទប់ស្កាត់លេងសត្វពាហនៈនៅតាមដងផ្លូវសាធារណៈ
- បង្កើនការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់ដោយសារផលពីការប្រើប្រាស់គ្រឿងញៀន
- ពង្រឹងវិធានការការពារថែរក្សាសុវត្ថិភាពសន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន
- បង្កើនការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាព[៣៩]
- បង្កើនកិច្ចសហការស្វែងរកមូលនិធិខាងក្រៅ និងប្រើប្រាស់មូលនិធិរដ្ឋបាលឃុំធ្វើការកែលម្អ និងសាងសង់ទីស្នាក់ការភូមិ។

---

[៣៧]មាត្រា៨៧ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[៣៨]ពលកម្មកុមារ ប្រភពក្រសួងការងារ ដាក់ចេញវិធានការដើម្បីបញ្ចប់ពលកម្មកុមារត្រឹមឆ្នាំ២០២៥

[៣៩]គោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាព

# ២.៤ ការគ្រប់គ្រងដីធ្លីបរិស្ថានសាធារណៈការនិងសោភ័ណភាព

## ២.៤.១ ការកាន់កាប់និងគ្រប់គ្រងដី

ចំណាត់ថ្នាក់ការប្រើប្រាស់ដីលំអិតក្នុងឃុំអូរឧកញ៉ាហេង[៤០]

| ល.រ | ប្រភពនៃការប្រើប្រាស់ដី | ក្រឡាផ្ទៃ(ហ.ត) | បរិយាយ |
|---|---|---|---|
| ១ | ដីលំនៅឋាន | ២៧២.១៦ | ដីសម្រាប់លំនៅឋានមានលាយដីសួនចម្ការហូបផ្លែ ឬចម្ការក្បែរផ្ទះ |
| ២ | ដីកសិកម្ម (ដីស្រែវស្សា) | ២,៤៥៤.៩១ | ដីស្រែដែលពឹងពាក់លើទឹកភ្លៀងទាំងស្រុង |
| ៣ | ស្រែលាយលំនៅឋាន | ១១៧.៣១ | |
| ៤ | ដីចម្ការ | ១០១.៧៧ | |
| ៥ | ចម្ការឈើហូបផ្លែ | ១,៤២៥.១៥ | |
| ៦ | ព្រៃដុះឡើងវិញ | ១.៤៩៩.២៣ | |
| ៧ | ព្រៃគម្ពោធ | ១៦៨.៧៩ | |
| ៨ | ព្រៃក្រោយមាត់សមុទ្រ | ៣៥៩.៤៤ | |
| ៩ | ព្រៃកោងកាង | ៣៧៧.៦១ | |
| ១០ | វាលកប់ខ្មោច | ៣៤.៣២ | |
| ១១ | ទីលានចាក់សម្រាម | ១.១៣ | |
| ១២ | បឹង | ៣២.០០ | |
| ១៣ | ស្រះទឹក | ៧.១៧ | |
| ១៤ | សមុទ្រ | ៣៥.៩៥ | |
| ផ្ទៃដីសរុប | | ៦,៨៨៦.៩៤ | |

តារាងនៃការប្រើប្រាស់ដីនាពេលអនាគតឆ្នាំ២០១៥-២០២៥ នៃចំណាត់ថ្នាក់ការប្រើប្រាស់ដីអនាគតលំអិតក្នុងឃុំអូរឧកញ៉ាហេង[៤១]

| ល.រ | ប្រភពនៃការប្រើប្រាស់ដី | ក្រឡាផ្ទៃនៅឆ្នាំ ២០១៥(ហ.ត) | ក្រឡាផ្ទៃនៅឆ្នាំ ២០២៥(ហ.ត) | បម្រែបម្រួល (ហ.ត) | សំគាល់ |
|---|---|---|---|---|---|
| ១ | ដីលំនៅដ្ឋាន | ២៧២.១៦ | ៣៤៩.៤៤ | ៧៧.២៨ | កំណើនប្រជាជន |
| ២ | ដីកសិកម្ម (ដីស្រែវស្សា) | ២,៤៥៤.៩១ | ២,៤៩២,៧៤ | -៣៨.៨៦ | តំរូវការដីលំនៅដ្ឋាន |
| ៣ | ស្រែលាយលំនៅដ្ឋាន | ១១៧.៣១ | ៧៦.៦៩ | -៤០.៦២ | តំរូវការដីលំនៅដ្ឋាន |
| ៤ | ដីចម្ការ | ១០១.៧៧ | ៦៤.១៧ | -៣៧.៦០ | តំរូវការដីលំនៅដ្ឋាន |
| ៥ | ចម្ការឈើហូបផ្លែ | ១,៤២៥.១៥ | ១,២៦២.៤១ | -១៦២.៧៤ | តំបន់ឧស្សាហកម្ម |

| | | | | | |
|---|---|---|---|---|---|
| ៦ | ព្រៃដុះឡើងវិញ | ១.៤៩៩.២៣ | ១,៥០៥.២០ | ៥.៩៧ | |
| ៧ | ព្រៃគម្លោច | ១៦៨.៧៩ | ១៣៤.៨២ | -៣៣.៩៧ | តម្រូវការទីលានចាក់សម្រាម |
| ៨ | ព្រៃក្រោយមាត់សមុទ្រ | ៣៥៩.៤៤ | ៣៥៩.៤៤ | 0.00 | |
| ៩ | ព្រៃកោងកាង | ៣៧៧.៦១ | ៣៧៧.៦១ | 0.00 | |
| ១០ | វាលកប់ខ្មោច | ៣៤.៣២ | 0.00 | -៣៤.៣២ | តំរូវការដីលំនៅដ្ឋាន |
| ១១ | ទីលានចាក់សម្រាម | ១.១៣ | ៦១.១៣ | ៦0.00 | |
| ១២ | បឹង | ៣២.00 | ៣.៥៧ | -២៨.៤៣ | តំបន់ទេសចរណ៍ធម្មជាតិ |
| ១៣ | ស្រះទឹក | ៧.១៧ | ៧.១៧ | 0.00 | |
| ១៤ | សមុទ្រ | ៣៥.៩៥ | ៣៥.៩៥ | 0.00 | |
| ១៥ | តំបន់ទេសចរអនាគត | | ២៨.២៤ | ២៨.២៤ | បឹង និង ព្រៃក |
| ១៦ | តំបន់ឧស្សាហកម្មអនាគត | | ១៧០.៧៣ | ១៧០.៧៣ | ចម្ការនិងឧស្សាហកម្ម |
| ផ្ទៃដីសរុប | | ៦,៨៨៦.៩៤ | ១០៣១៥ | ៣,៤២៨.០៦ | ពង្រីកដីឃុំ |

តាមប្រភពឯកសារផែនការអភិវឌ្ឍឃុំឧកញ៉ាហេងឆ្នាំ ២០១៣-២០១៧ បានដឹងថា ២០១២ វិវាទដីធ្លីចំនួន ៧ករណីឆ្នាំ២០១៤ មានវិវាទដីធ្លីចំនួន ៨ករណី ឆ្នាំ២០១៥ មានវិវាទដីធ្លីចំនួន ១២ករណី ឆ្នាំ២០១៦ មានចំនួន ១៥ករណី។

ជាទូទៅនៅក្នុងឃុំអូរឧកញ៉ាហេងមានប្រជាពលរដ្ឋកាន់កាប់ដីគ្នាដែលបន្តមកពីសម័យមុនពោលគឺមិនទាន់មានការចុះបញ្ជីកម្មសិទ្ធិដីធ្លីឡើងវិញនៅឡើយទេ។ បានព័ត៌មានអំពីស្ថានភាពនៃការប្រើប្រាស់ដីខាងលើយើងអាចយល់បានថា បច្ចុប្បន្ននៅឃុំអូរឧកញ៉ាហេងបំពុលខ្លាំងទៅលើកសិកម្មដែលមានទំហំដីរហូតដល់ ៣៤.៧៣% នៃផ្ទៃដីក្នុងឃុំទាំងមូល ប្រើប្រាស់ដីសម្រាប់កសិកម្មហើយនិងការប្រើប្រាស់ដីពុំមានបញ្ហាទំនាស់ច្រើនឡើយប្រជាពលរដ្ឋបន្តនិរន្តរភាពកាន់កាប់ដីធ្លីតាំងពីសម័យមុនមក។ ទន្ទឹមនឹងនេះក៏ពិនិត្យឃើញនៅបច្ចុប្បន្នជាមធ្យមក្នុងមួយគ្រួសារមានផ្ទៃដីលំនៅដ្ឋានប្រមាណ ០.១៦ ហិតា ដែលជាចំនួនមួយសមស្របបើយោងតាមអនុក្រឹត្យស្តីអំពីដីសម្បទានសង្គមកិច្ចលេខ ១៩ អនក្របកចុះថ្ងៃទី ១៩ ខែសីហាឆ្នាំ ២០០៣ ជំពូកទី ៥ មាត្រា១៦ បានចែងថា ដីសម្បទានសង្គមកិច្ច ត្រូវផ្តល់ឲ្យសម្រាប់លំនៅឋានមានទំហំពី ១២០០ ទៅ ៣៦០០ ម៉ែត្រការ៉េ។

---

[៤០]ចំណាត់ថ្នាក់ការប្រើប្រាស់ដីលំអិតក្នុងឃុំអូរឧកញ៉ាហេង ប្រភពភពទិន្នន័យៈ ក្រុមការងារ GIS ឆ្នាំ២០១៥

[៤១]តារាងនៃការប្រើប្រាស់ដីនាពេលអនាគតឆ្នាំ២០១៥-២០២៥ ចំណាត់ថ្នាក់ប្រើប្រាស់ដី ដកស្រង់ពីសៀវភៅផែនការប្រើ

យោងតាមសេចក្តីអត្ថាធិប្បាយពីការប្រើប្រាស់ដីទៅអនាគតសម្រាប់ ២០១៥-២០២៥ ការប្រើប្រាស់ដីនៅក្នុងឃុំអូរឧកញ៉ាហេង ត្រូវបានបែងចែកជា៦ប្រភេទសំខាន់ៗផ្សេងៗគ្នាសម្រាប់ពេលអនាគតទៅលើផ្ទៃដីសរុបចំនួន ៦.៥៣៧ ហ.ត (ទិន្នន័យ GIS ៦.៨៨៦,៩៤ ហិតា) ដូចខាងក្រោម៖

- ប្រភេទដីលំនៅឋានមានផ្ទៃដីចំនួន ២៤៥ ហិតា (ទិន្នន័យ GIS ៣៤៩,៤៤ហិតា) ប្រាស់ដី
- ប្រភេទដីតំបន់ឧស្សាហកម្ម មានផ្ទៃដីចំនួន ១៧០,៧៣ហិតា
- ប្រភេទដីស្រែមានផ្ទៃដីចំនួន ៩៧០ហិតា (ទិន្នន័យ GIS ២.៤១៦,០៥ ហិតា)
- ប្រភេទដីចម្ការបន្លែមានផ្ទៃដីចំនួន ៣០០ហិតា (ទិន្នន័យ GIS ៦៤,១៧ ហិតា)
- ប្រភេទដីចម្ការឈើហូបផ្លែមានផ្ទៃដីចំនួន ១.០០០ ហិតា (ទិន្នន័យ ១.២៦២,៤១ ហិតា
- ប្រភេទដីព្រៃដែលមានព្រៃភ្នំទំហំ ១.៦៤០,០២ ហិតា និងដីព្រៃលិចទឹកមានទំហំ ៧៣៧,០៥ហ.ត

យោងតាមរបាយការណ៍ ស្តីពីការកាត់ផ្ទៃដីមួយនៃឃុំរាម មកដាក់បញ្ចូលក្នុងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ក្នុងឆ្នាំ២០១៨ ពីផ្ទៃដីទំហំ ៦.៨១០ ហិតា មកទំហំ ១០.៣១៥ ហិតា។

### ២.៤.២ បរិស្ថាន និងធនធានធម្មជាតិ

ដោយទឹកដីឃុំអូរឧកញ៉ាហេង ជាប់ជាមួយនិងតំបន់ភ្នំ និងសមុទ្រ ដូចនេះទឹកដីមួយផ្នែកជាតំបន់ព្រៃលិចទឹកជាពិសេសស្ថិតតំបន់ឧទ្យានជាតិរាម គឺសម្បូរទៅដោយធនធានធម្មជាតិ ដូចជា ព្រៃឈើ សត្វព្រៃ មច្ឆាជាតិ និងពពួកជីវៈចម្រុះគ្រប់ប្រភេទនៅក្នុងទឹក និងលើគោក។

#### ក. ធនធានដី

ព័ត៌មានពីផែនការអភិវឌ្ឍឃុំនៅ ២០១៥-២០១៧ បានឲ្យដឹងថា ឃុំអូរឧកញ៉ាហេង មានគ្រួសារកសិកររហូតដល់ ២៨១គ្រួសារ ស្មើនិង ១៧,៨៩% ប្រើប្រាស់ជីគីមី និង ៤២៤ គ្រួសារ ត្រូវនិង ២៦,៩៩% ប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិតនិងស្មៅសម្រាប់ការដាំដុះ។ នេះបានបង្ហាញថា ផ្នែកសិករ មិនសូវមានជីវជាតិ និងមានការបំផ្លាញ់ ពីសត្វល្អិតចង្រៃផង ដែលធ្វើឲ្យទិន្នន័យកសិករ ទទួលបានផលត្រឹមមធ្យម ជាពិសេសស្រូវស្សា។ ផ្ទៃដីស្រែវស្សាបំផ្លាញ់ដោយសត្វល្អិតមានចំនួន ៣១ ហិតា និងមានបញ្ហាទឹកប្រៃហូរចូលដីស្រែ។

#### ខ. ធនធានទឹក

តាមប្រភពព័ត៌មានដកស្រង់ពីផែនការអភិវឌ្ឍឃុំឆ្នាំ២០១៣-២០១៧ បានឲ្យដឹងថា មានប្រជាជន ៥,៧៥% មានមុខរបរចម្បងជាអ្នកនេសាទ និង០,០៤% ជាអ្នកប្រកបរបរអនុផលព្រៃឈើ និង០,៤៩% ជាអ្នកប្រកបរបរកដាំដំណាំរយៈវែងនៅលើផ្ទៃដីព្រៃ ដែលជាដីព្រៃលិចទឹកនិងជាព្រៃរក្សាទុក។ ទន្ទឹមនិងនោះ ផលប៉ះពាល់មួយគឺ ការហូរចូលនៃទឹកប្រៃទៅក្នុងស្រែ។ មានអាងស្តុកទឹកយ៉ាងធំនៅចន្លោះភូមិបត់គគីរ និងភូមអូរចំណារដែល អាចផ្គត់ផ្គង់សម្រាប់រដូវប្រាំងដល់ផ្ទៃដីផ្នែកខាងត្បូងផ្លូវជាតិលេខ៤ ប៉ុន្តែត្រូវការជុសជុលទ្វារទឹក និងទំនប់។

#### គ. ធនធានព្រៃឈើ

មានប្រភពព័ត៌មានដកស្រងពីស្ថានភាពឃុំឆ្នាំ២០១៥ បានឲ្យដឹងថា មានប្រជាជន០,០៥% ជាអ្នកប្រកបរបរអនុផលព្រៃឈើ និង០,៤៩ ជាអ្នកប្រកបរបរដាំដំណាំរយៈពេលវែងនៅផ្ទៃដីព្រៃ ដែលជាព្រៃលិចទឹក និងជាព្រៃរក្សាទុក។ ដោយសារកំណើនប្រជាពលរដ្ឋមកបោះទីតាំងសាងសង់លំនៅដ្ឋាន រស់នៅតាមតំបន់មាត់

ព្រៃក និងការប្រកបអាជីវកម្ម ការបំផ្លាញព្រៃលិចទឹកដើម្បីជីវភាពរបស់ពលរដ្ឋ និងការអភិវឌ្ឍមួយចំនួនបានបង្ហាញពីការបាត់បង់ធនធានធម្មជាតិ។

**ឃ. ធនធានជលផល**

តាមប្រភពព័ត៌មានដកស្រង់ពីផែនការអភិវឌ្ឍឃុំ ២០១៣-២០១៧ បានឲ្យដឹងថាមានប្រជាជនមានមុខរបរចម្បងជាអ្នកនេសាទនិង និង ០,០៤% ជាអ្នកប្រកបរបរអនុផលព្រៃឈើ និង ០,៤៩% ជាអ្នកប្រកបរបរកសិកម្មរយៈពេលវែងនៅលើផ្ទៃដីព្រៃនិងជាព្រៃទឹកលិចរក្សាទុក។ ដោយសារតែកំណើនប្រជាពលរដ្ឋមកបោះទីតាំងសាងសង់លំនៅដ្ឋាន រស់នៅតាមតំបន់មាត់ព្រៃក និងប្រកបរបរអាជីវកម្ម ការបំផ្លាញព្រៃលិចទឹកដើម្បីជីវភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមួយចំនួន បានបង្ហាញពីការបាត់បង់ធនធានធម្មជាតិ ។ ហើយផលប៉ះពាល់មួយទៀតគឺ ការនេសាទដោយប្រើឧបករណ៍ខុសច្បាប់ និងការនេសាទនៅក្នុងរដូវហាមឃាត់។

**ង. ធនធានរ៉ែ**

នៅក្នុងឃុំអូរឧកញ៉ាហេងពុំមានការសិក្សាស្រាវជ្រាវណាបង្ហាញពីវត្តមានធនធានរ៉ែធម្មជាតិឡើយ ប៉ុន្តែមានគ្រោះក្រហមនឹងដីឬល្បាយថ្មសម្រាប់ធ្វើគ្រឹះផ្លូវ និងផ្លូវដីក្រហម។ ប្រសិនបើត្រូវការសាងសង់សំណង់នានាត្រូវដឹកជញ្ជូនសម្ភារៈសំណង់ពីក្រៅស្រុកដូចជា ថ្មនិងខ្សាច់ អាចយកមកពីស្រុកភ្នំស្រួចក្នុងខេត្តកំពង់ស្ពឺជាដើម។

## ២.៤.៣ សាធារណការ និងសោភ័ណភាពសង្គម

ការប្រាស័យទាក់ទងពីឃុំមួយទៅឃុំមួយ និងពីភូមិមួយទៅភូមិមួយក្នុងឃុំធ្វើដំណើររបស់ប្រជាពលរដ្ឋការដឹកជញ្ជូនផលិតផលកសិកម្ម និងសម្ភារៈនានាបានដំណើរទៅដោយប្រើប្រាស់ផ្លូវលំដីក្រហមដែលជាបណ្ដាញភ្ជាប់រវាងភូមិទាំង ៥ របស់ឃុំនៅក្នុងទីប្រជុំជននឹងទីរួមស្រុក។ ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំឆ្នាំ ២០១៥ បានឲ្យដឹងថាចម្ងាយផ្លូវពីភូមិទៅសាលាឃុំអូរឧកញ៉ាហេងមានប្រវែង ២០៥ គីឡូម៉ែត្រ ចម្ងាយផ្លូវជាមធ្យមពីភូមិទៅសាលាស្រុកព្រៃនប់មានប្រវែងប្រមាណ ១៤,៨០គីឡូម៉ែត្រ និងចម្ងាយផ្លូវជាមធ្យមពីភូមិទៅសាលាខេត្តមានប្រមាណ ១៣,២០គីឡូម៉ែត្រ ។ ឃុំមានផ្លូវជាតិ (ខេត្ត) ឆ្លងកាត់ប្រវែង ១០.៤៩៣ ម៉ែត្រ ដែលជាប្រភេទផ្លូវចាក់កៅស៊ូ។

តាមព័ត៌មានពីប្រភពឯកសារផែនការអភិវឌ្ឍន៍ឃុំឆ្នាំ ២០១៣-២០១៧ បានឲ្យដឹងថា ផ្លូវខេត្តឆ្លងកាត់មានការខូចខាតតិចតួចដែលតម្រូវឲ្យមានការជួសជុលតូចតាចចំណែកផ្លូវដីក្រហមក្នុងឃុំមានការខូចខាតឡើងវិញជាច្រើនដែលនាំឲ្យពិបាកក្នុងការធ្វើដំណើរជាពិសេសពិបាកនៅរដូវវស្សា ប៉ុន្តែរយៈពេលនៃការខូចខាតទាំងស្រុងគឺរហូតដល់ទៅ ៣ ទៅ ៤ ឆ្នាំឯណោះ។ ផ្លូវក្នុងឃុំទាំងអស់ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ដោយមធ្យោបាយនានា។

បច្ចុប្បន្ននេះឃុំអូរឧកញ៉ាហេងមានផ្លូវក្រាលបេតុងចំនួន៥ខ្សែ ស្ថិតនៅភូមិអូរឧកញ៉ាហេងចំនួន១ខ្សែ ភូមិបត់គគីរចំនួន១ខ្សែរ អូរតាប៉ាងចំនួន១ខ្សែ និងភូមិអូរចំណារចំនួន២ខ្សែ។

## តារាងផែនការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមសម្រាប់ឆ្នាំ ២០១៥-២០២០

| ផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | |
|---|---|---|---|
| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំ២០១៥ (ម៉ែត្រ) | ប្រវែងផ្លូវរហូតដល់ឆ្នាំ ២០២៥(គ.ម) | មប្រែប្រួល |
| ផ្លូវក្រាលកៅស៊ូ | ១០.៩៧៦ | ១០.៩៧៦ | ០ |
| ផ្លូវក្រាលបេតុង | ០ | ៤៧,០៦៨ | ៤៧,០៦៨ |
| ផ្លូវក្រាលក្រួសក្រហម | ៥.២៧០ | ១៥,៨២៧ | ១០,៥៥៧ |
| ផ្លូវលំដីស | ០ | ៩,៣៧០ | ៩,៤១៤ |
| ផ្លូវរទេះ/ថ្មើរជើង | ៤.៥០០ | ២៦,៨៧០ | ២២,៣៧០ |
| តំបន់/ប្រឡាយមេ | ២ | ៥ | ៣ |
| តំបន់/ប្រឡាយរង | ២ | ២ | ០ |
| ប្រវែង/ចំនួនលូ | ១១កន្លែង | ២៤ | ១៣ |
| ប្រវែង/ចំនួនស្ពាន | ០ | ១ | ១ |
| ប្រវែងចំនួនទ្វារទឹក | ០ | ៣ | ៣ |
| ផែនការផ្នែកសេវាកម្មសង្គម | | | |
| ប្រភេទសេវាកម្ម | ចំនួនក្នុងឆ្នាំ២០១៥ | ចំនួនក្នុងឆ្នាំ២០២៥ | បម្រែបម្រួល |
| សាលាមត្តេយ្យ | ៤ថ្នាក់ | ១៣ថ្នាក់ | ៩ថ្នាក់ (សង់បន្ថែម១ខ្នង) |
| សាលាបឋមសិក្សា | ១៣ថ្នាក់ | ២៣ថ្នាក់ | ១០ថ្នាក់ (សង់បន្ថែម ២ខ្នង) |
| អនុវិទ្យាល័យនិងវិទ្យាល័យ | ១០ថ្នាក់ | ២១ថ្នាក់ | ១១ថ្នាក់ (សង់បន្ថែម ១ខ្នងមាន២ជាន់) |
| មន្ទីរពេទ្យបង្អែក | ០ | ០ | ០ |
| មណ្ឌលសុខភាព | ០១ | ០១ | ០ |
| ទីតាំងផ្សារឃុំ | ០១ | ០១ | ០ |
| កន្លែងចាក់សម្រាម | ០១ | ០១កន្លែង | ០ |

## ២.៥ រដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ២.៥.១ អភិបាលកិច្ច

ដោយការបោះឆ្នោតជាសកល និងក្រោយប្រកាសសុពលភាពក្រុមប្រឹក្សាឃុំបានពង្រឹងតួនាទីភារកិច្ចក្រុមប្រឹក្សាឃុំបាន និងកំពុងអនុវត្តឲ្យបានសម្រេចតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ និងបន្តអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ការអនុវត្តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។ បានរៀបចំរចនាសម្ព័ន្ធរដ្ឋបាលឃុំតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ត្រូវបានពង្រឹងអភិបាលកិច្ចបង្កើនសមត្ថភាពក្រុមប្រឹក្សា និងពង្រឹងការអនុវត្តតួនាទីភារកិច្ចស្មៀនដើម្បីបង្កិតសេវាសាធារណៈឲ្យជិតប្រជាពលរដ្ឋលើកស្ទួយកិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋប្រកបដោយ សុចរិតភាពតម្លាភាព និងគណនេយ្យភាពចំពោះការគ្រប់គ្រង និងការប្រើប្រាស់ថវិកា។

### ២.៥.២ គ្រប់គ្រងដែនដី

បច្ចុប្បន្នដែនដីរដ្ឋបាលការប្រើប្រាស់ដី[៤២] សម្រាប់តំបន់លំនៅដ្ឋានពុំបានត្រឹមត្រូវគ្មានរបៀបរៀបរយស្របតាមទៅនឹងស្ថានភាពដី ឬតាមនគរូបនីយកម្មបញ្ញត្តិទីប្រជុំជនឡើយ។ ដីសាងសង់លំនៅដ្ឋានភាគច្រើនដើរតាមដោយផ្លូវសំខាន់ប្រជាពលរដ្ឋមួយចំនួនទៀតបានមកតាំងទីលំនៅលើដីសាធារណៈតាមដីចំនីផ្លូវហ្វឹងម៉ូតឧទ្យានជាតិ។

ផ្ទៃដីឃុំស្ថិតនៅក្នុងតំបន់ការពារឧទ្យានព្រះសីហនុរាមនេះ ពលរដ្ឋនៅក្នុងឃុំមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីគ្រប់គ្រួសារដែលនាំអោយមានករណីទំនាស់កើតឡើង។ ទន្ទឹមនោះក៏មានភាពអនាធិបតេយ្យការទន្ទ្រានដីព្រៃយកធ្វើជាកម្មសិទ្ធិនៅតែជាបញ្ហាប្រឈមរបស់រដ្ឋបាលឃុំ។

### ២.៥.៣ ការគ្រប់គ្រងស្ថិតិ

ជំរុញការផ្សព្វផ្សាយយ៉ាងទូលំទូលាយជាសាធារណៈដល់ប្រជាពលរដ្ឋដើម្បីបង្កើនការយល់ដឹងដល់ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងពីសារៈប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋានសម្រាប់ពលរដ្ឋម្នាក់ម្នាក់ដែលរស់នៅក្នុងប្រទេសជានីតិរដ្ឋ។

បច្ចុប្បន្នកុមារបានមកចុះបញ្ជីសំបុត្រកំណើត (ក្រោយកើត ៣០ ថ្ងៃ) មាន ៩៤,២០%។

### ២.៥.៤ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ប្រជាពលរដ្ឋរស់នៅប្រកបដោយសុវត្ថិភាព និងមានសន្តិសុខសណ្តាប់ធ្នាប់ល្អដោយយើងបានអនុវត្តនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាពតាមរយៈការបង្កើត និងពង្រឹងប្រជាការពារតាមភូមិ ការពង្រឹងកិច្ចសហការជាមួយបណ្តាស្ថាប័នជំនាញ និងអង្គការនានាធ្វើការអប់រំផ្សព្វផ្សាយដល់ពលរដ្ឋបានយល់ដឹងពីច្បាប់នានាដែលពាក់ព័ន្ធដល់ការអនុវត្តនិងសន្តិសុខសណ្តាប់ធ្នាប់សង្គម ដែលជាមូលដ្ឋានកាត់បន្ថយនូវភាពអស្ថេរភាពក្នុងមូលដ្ឋានទូទាំងឃុំដូចជាៈ ករណីចោរកម្មករណីទំនាស់ដីធ្លី ការជួញដូរមនុស្ស ក្រុមក្មេងទំនើង ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន។ល។

[៤២]ការប្រើប្រាស់ដី ប្រភពពី ផែនការប្រើប្រាស់ដីឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ការងាររដ្ឋបាលបច្ចុប្បន្នឃុំមានមូលដ្ឋានសម្រាប់ធ្វើការទំនាក់ទំនងបានល្អប្រសើរដោយមានទីតាំងនៅក្បាលឃុំមួយសម្រាប់ផ្តល់ការទំនាក់ទំនងទៅថ្នាក់ភូមិ និងអាចមានលទ្ធភាពផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានសហគមន៍ទូទាំងឃុំ។

- ផលធៀបចំនួនគ្រួសារមានអំពើហិង្សាក្នុង ១០០០គ្រួសារមាន២.២នាក់
- ផលធៀបជនរងគ្រោះនិងស្លាប់ដោយអំពើហិង្សាក្នុងគ្រួសារក្នុង ១០០០គ្រួសារមាន ១២គ្រួសារ
- ផលធៀបគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀនក្នុង ១០០០គ្រួសារមាន ២,៨ គ្រួសារ
- ចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ០៣នាក់
- ពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពពុំបានទូលំទូលាយដល់មូលដ្ឋានសហគមន៍។

# ជំពូកទី ៣

# គោលនយោបាយនិងសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១៥ - ២០២០

## ៣.១ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ

យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- បង្កើនផ្សព្វផ្សាយច្បាប់ភូមិបាល និងច្បាប់នានាបង្រឹងការអនុវត្តច្បាប់ភូមិបាល និងជំរុញការចុះវាស់វែង និងផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ។
- បង្កើនការយល់ដឹងពីច្បាប់ប្រើប្រាស់ពលកម្មកុមារ ការជួញដូរមនុស្ស នឹងពង្រឹងវិធានការទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់ពលកម្មកុមារ ។
- បង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហឹង្សា បង្រឹងវិធានការអប់រំទប់ស្កាត់នៅគ្រប់សហគន៍ និងបង្កើនសកម្មភាពជួយសង្គ្រោះជនរងគ្រោះ បន្តពង្រឹងការជួយឧបត្ថដល់គ្រួសារក្រីក្រ បន្តកិច្ចសហការជួយថែរក្សាគាំពារសុខភាព និងសុខមាលភាពរបស់គាត់ អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋភិបាលសហការផ្តល់ជំនាញចំនេះដឹង និងការជួយផ្តល់ទុនសម្រាប់បង្កើតមុខរបរ ។
- បង្កើនការផ្តល់ចំណេះដឹងស្តីពីការលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ ។
- បង្កើនការយល់ដឹងពីសារប្រយោជន៍នៃអត្រានុកូលដ្ឋាន ជំរុញការផ្តល់សេវា និងការបង្កើនការផ្សព្វផ្សាយពលរដ្ឋឲ្យមកទទួលយកសេវាអត្រានុកូលដ្ឋាន ។
- បង្កើនការយល់ដឹងពីច្បាប់ បង្រឹងវិធានការអនុវត្តច្បាប់ចរាចរណ៍ ។
- បង្កើនការផ្សព្វផ្សាយ និងពង្រឹងវិធានការទប់ស្កាត់ការលែងសត្វពាហនៈនៅតាមដងផ្លូវសាធារណៈ ។
- បង្កើនការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់ដោយសារផលពីការប្រើប្រាស់គ្រឿងញៀន ។
- ពង្រឹងវិធានការការពារថែរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន ។
- បង្កើនការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។
- បង្កើនកិច្ចសហប្រតិបត្តិការស្វែងរកមូនិធិខាងក្រៅ និងប្រើប្រាស់មូលនិធិរដ្ឋបាលឃុំធ្វើការកែលម្អរនិងសាងសង់ស្នាក់ការភូមិ ។

តារាងក្របខណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ[៤៣]

| ល.រ | កម្មវិធីអភិវឌ្ឍន៍ | ឆ្លើយតមគោលដៅ | បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប | |
| ក. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ១ | ការសាងសង់និជួសជុលផ្លូវប្រវែង១,២៥០ម | ១.៣.១ | ផ្លូវបេតុង | ម | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ១០០ | |
| ២ | សាងសង់ដាក់លូប្រវែង២៥០ម | ១.៣.១ | ដាក់លូកាត់ផ្លូវ | ម | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ២៥០ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ខ.ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| ១ | គាំទ្រដំណើការមត្តេយ្យសហគមន៍ ៥ថ្នាក់ក្នុងមួយឆ្នាំ | ២.១.២ | ឧបត្ថម្ភគ្រូ | នាក់ | ៥ | ៥ | ៥ | ៥ | ៥ | ២៥ | |
| | | | គាំទ្រសម្ភារសិក្សាថ្នាក់មត្តេយ្យ | នាក់ | ៥ | ៥ | ៥ | ៥ | ៥ | ២៥ | |
| ២ | បញ្ហាបយេនឌ័រ | ៤.២.១ | អប់រំផ្សព្វផ្សាយបញ្ច្រាបយេនឌ័រ | លើក | ៥ | ៥ | ៥ | ៥ | ៥ | ២៥ | |
| គ.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| ១ | ការគ្រប់គ្រងសំអាតបរិស្ថាន | ៣.៣.២ | សំអាតបរិស្ថានតាមដងផ្លូវសាធារណៈ | លើក | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ១២០ | |
| ឃ.ផ្នែករដ្ឋបាល និងសន្តសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| ១ | ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព | ៤.៥.១<br>៤.៥.២<br>៤.៥.៣ | អប់រំផ្សព្វផ្សាយពីសុវ ត្ថិភាពសណ្តាប់ធ្នាប់សាថារណៈ | លើក | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១២៥ | |

## តារាងក្របខណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ[៤៤]

| លរ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប | |
| ១ | សំបុត្រកំណើត | សន្លឹក | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៥០០ | |
| ២ | សំបុត្របញ្ជាក់កំណើត | សន្លឹក | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ១៥០០ | |
| ៣ | សំបុត្រអាពាហ៍ពិពាហ៍ | សន្លឹក | ២០ | ២០ | ២០ | ២០ | ២០ | ១០០ | |
| ៤ | សំបុត្រមរណភាព | សន្លឹក | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ២០០ | |
| ៥ | សេចក្តីចម្លងសំបុត្រកំណើត | សន្លឹក | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១២៥ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | សន្លឹក | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១២៥ | |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | សន្លឹក | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១២៥ | |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | សន្លឹក | ២៥ | ២៥ | ២៥ | ២៥ | ២៥ | ១២៥ | |
| ៩ | លិខិតបញ្ជាក់លំនៅដ្ឋាន | សន្លឹក | ៥ | ៥ | ៥ | ៥ | ៥ | ២៥ | |
| ១០ | លិខិតបញ្ជាក់ភាពនៅលីវ | សន្លឹក | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ២៥០ | |

តារាងលិខិតបទដ្ឋានគតិយុត្តរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ[៤៥]

| លរ | ប្រភេទសេវារដ្ឋបាល | ឯកតា | លទ្ធផលប៉ាន់ស្មាន | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប | |
| ១ | ដីកា | ច្បាប់ | ១ | ១ | ១ | ១ | ១ | ៥ | |
| ២ | សេចក្តីសម្រេច | ច្បាប់ | ៧ | ៧ | ៧ | ៧ | ៧ | ៣៥ | |
| ៣ | សេចក្តីជូនដំណឹង | ច្បាប់ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ៧៥ | |

## ៣.២ កម្មវិធីវិនិយោគបីឆ្នាំរំកិល

ការតាមដាន និងការវាយតម្លៃអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាសកម្មភាពដែលផ្តោតលើការសន្និដ្ឋានពីស្ថានភាពដីនិងលទ្ធផលនៃការអនុវត្តៈ

- គម្រោងសកម្មភាពកំពុងដំណើរការ
- គម្រោងសកម្មភាពដែលមានថវិកាគាំទ្រ
- គម្រោងសកម្មភាពអាទិភាពដែលមិនទាន់ថវិកាគាំទ្រ
- តើមានការគាំទ្រគម្រោងសកម្មភាពថ្មីបន្ថែមក្រៅពីគម្រោងសកម្មភាពដែលមិនទាន់មានការសន្យាគាំទ្របុទេ

[៤៣]តារាងក្របខណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបសរដ្ឋបាលឃុំ សៀវភៅ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ

[៤៤]តារាងក្របខណ្ឌផ្តល់សេវារដ្ឋបាលរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ សៀវភៅ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ

[៤៥]តារាងលិខិតបទដ្ឋានគតិយុត្តរយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ សៀវភៅ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ

- ការផ្តល់សេវារដ្ឋបាល
- ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា

### ៣.២.១ យន្តការតាមដាននិងវាយតម្លៃ

- ប្រធានក្រុមប្រឹក្សាត្រូវបែងចែកសមាជិកក្រុមប្រឹក្សាចុះពិនិត្យ និងតាមដានគ្រប់សកម្មភាពអនុវត្តគម្រោងនានាដែលមានក្នុងកិច្ចព្រមព្រៀងដល់សន្យា នឹងការគាំទ្រដោយសិក្ខាសាលាសមាហរណកម្មនៅក្នុងស្រុក។
- ជនបង្គោលទទួលបន្ទុកស្ត្រីកុមារឃុំតាមដានពិនិត្យលើការអនុវត្តសកម្មភាពយេនឌ័រនិងបរិយាបន្ន
- គ.ផ.ថ រៀបចំកិច្ចប្រជុំពិនិត្យរបាយការណ៍រីកចម្រើននៅក្នុងឆ្នាំនីមួយៗដើម្បីវាយតម្លៃការពិនិត្យពីការអនុវត្តគម្រោងរបស់អ្នកពាក់ព័ន្ធ។
- ស្មៀនសង្កាត់ត្រូវរៀបចំបូកសរុបរបាយការណ៍រីកចម្រើនជូនក្រុមប្រឹក្សា។
- ការិយាផែនការស្ថិតិស្រុកទទួលបន្ទុកផ្តល់នូវឯកសារមានស្តីពីលទ្ធផលនៃការអនុវត្តគម្រោង
- អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធនានាត្រូវផ្តល់របាយការណ៍លទ្ធផលអនុវត្តសកម្មភាពនានាដែលមានការគាំទ្រក្នុងសមាហរណកម្មកម្មវិធីវិនិយោគក្នុងឆ្នាំនីមួយៗដល់រដ្ឋបាលឃុំ។

### ៣.២.២ វិធីសាស្ត្រតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សា គ.ផ.ថ ឃុំ បានកំណត់នូវវិធីសាស្ត្រនានាដែលត្រូវប្រើប្រាស់សម្រាប់ការតាមដាននិងការវាយតម្លៃការសម្រេចនូវគម្រោងដែលមានការគាំទ្រក្នុងសិក្ខាសាលាសមាហរណកម្មផែនការនៅថ្នាក់ឆ្នាំ ២០១៨ តាមតារាងតាមដានការអនុវត្តគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

1. ក្រុមប្រឹក្សានិង គ.ផ.ថ ត្រូវធ្វើការផ្ទៀងផ្ទាត់និងប្រៀបធៀបតាមរយៈ ៖
   - ចុះតាមដានត្រួតពិនិត្យដោយផ្ទាល់នៅអនុវត្តគម្រោងមូលនិធិឃុំនិងគម្រោងដៃគូអភិវឌ្ឍន៍
   - សហការជាមួយបណ្តាមន្ទីរ អង្គភាព និងដៃគូអភិវឌ្ឍដើម្បីប្រមូលព័ត៌មានស្តីពីការអនុវត្តគម្រោងការិយាល័យផែនការស្រុកត្រូវផ្តល់ព័ត៌មានលទ្ធផលអនុវត្តន៍គម្រោងដែលធ្វើការបូកសរុបក្នុងប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ។
2. ក្រុមប្រឹក្សានិង គ.ផ.ថ ឃុំត្រូវធ្វើការបូកសរុប ៖
   - របាយការណ៍សមិទ្ធផលរបស់ការិយាល័យជំនាញ
   - របាយការណ៍សមិទ្ធផលដែលជនបង្គោលចុះតាមដានការអនុវត្តសកម្មភាពនានា

### ៣.២.៣ សូចនាករតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សា គ.ផ.ថ ឃុំ ត្រូវស្រង់ចេញពីតារាងតាមដានការអនុវត្តគម្រោងនៃសកលនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០១៩-២០២១) តារាងការផ្តល់សេវា ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលឃុំមកពិនិត្យធ្វើការតាមដាននិងវាយតម្លៃសម្រាប់ប្រើប្រាស់ជាខ្នាតដើម្បីវាស់វែងអំពីវឌ្ឍនភាពនានា។

តារាងសង្ខេបប្រភពមូលនិធិឆ្នាំ២០១៩ នៃគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ[៤៦]

| ល.រ | ស្ថាប័ន | ចំនួនគម្រោងសកម្មភាព | សរុបតម្លៃគម្រោងសកម្មភាព (លានរៀល) | ប្រភពប្រមូលមូលនិធិ | ចំនួនគម្រោងសកម្មភាព | តម្លៃគម្រោងសកម្មភាព (លានរៀល) |
|---|---|---|---|---|---|---|
| ១ | រដ្ឋបាលសង្កាត់ | ២ | ១១១.១៣ | ឃុំ | ២ | ១១១.១៣ |
| ២ | ការគាំទ្រពីបណ្តាមន្ទីរ អង្គភាព | | | | | |
| ២.១ | មន្ទីរកសិកម្ម | ៥ | ២២ | ថវិកាជាតិ | ៥ | ២២ |
| ២.២ | មន្ទីរសុខាភិបាល | ១៤ | 87 | ថវិកាជាតិ | 14 | 87 |
| ២.៣ | កងរាជអាវុធហត្ថ | ៧ | 30 | ថវិកាជាតិ | 7 | 30 |
| ២.៤ | ស្នងការនគរបាល | ១៥ | 70 | ថវិកាជាតិ | 15 | 70 |
| ២.៥ | មន្ទីរអប់រំ | ៤ | 20 | ថវិកាជាតិ | 4 | 20 |
| សរុបមន្ទីរ/អង្គភាព | | ៤៥ | 229 | | 45 | 229 |
| ៣ | ការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃគូរអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ | | | | | |
| ៣.១ | អង្គការ... | | | | | |
| ៣.២ | អង្គការ... | | | | | |
| សរុបអង្គការ ដៃគូរ... | | | | | | |
| សរុបរួម (១+២+៣) | | ៤៧ | ៣៤០.១៣ | | ៤៧ | ៣៤០.១៣ |

## ៣.៣ កម្មវិធីវិនិយោគឃុំ

ថវិកាឃុំសម្រាប់អភិវឌ្ឍឆ្នាំ ២០១៥ ដែលវិភាជន៍ពីរដ្ឋាភិបាលមានចំនួន ៦០.៥០០.០០០រៀល និងថវិកាបដិភាគរបស់ពលរដ្ឋមានចំនួន ៥០០.០០០រៀល ក្រុមប្រឹក្សានិង គ.ជ.ថ ឃុំ សម្រេចធ្វើការវិនិយោគលើគម្រោងស្ពានផ្លូវក្រាលគ្រប់ក្រហមប្រវែង ២០០០ ម៉ែត្រ ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបានគោលដៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

[៤៦]តារាងសង្ខេបប្រភពមូលនិធិឆ្នាំ២០១៩ នៃគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ឆ្នាំ២០១៩ ២០២១

ថវិកាវិនិយោគតាមប្រភព[៤៧](ឯកតាពាន់រៀល)

| លរ | ប្រភព | ឆ្នាំ២០១៥ | ភាគរយ |
|---|---|---|---|
| ១ | ចំណូលផ្ទាល់របស់ឃុំ សង្កាត់ | | |
